ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១៩-២០

19-20

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ




ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

# បញ្ជីរឿង

ទំព័រ

១ — វិទ្យុធម្មទេសនា ក្រុងភ្នំពេញ កណ្ឌទី ១០ លោកអាចារ្យ ញូង-សឿង ក្រុមជំនុំព្រះត្រៃបិដក សំដែង . . . . . . . . . . . . . . . . . . . . ១

២ — ច្បាប់ស្រី ចំឡងចេញពោះពុម្ពផ្សាយអំពីច្បាប់សាស្ត្រស្លឹករឹត . . . . . . . ១៤

៣ — ច្បាប់អរិយសច្ចា ចំឡងចេញពោះពុម្ពផ្សាយអំពីច្បាប់សាស្ត្រស្លឹករឹត . . . . . ២៦

៤ — សេចក្ដីសង្ខេបនៃគម្ពីរបញ្ចតន្ត្រ . . . . . . . . . . . . . . . . . ៣១

៥ — ពង្សាវតារខេមរ, ស្រង់ចេញពីគោលបារីកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) . ៣៧

៦ — ភូមិសាស្ត្រសង្ខេប ប្រទេសអាមេរិកខាងត្បូង . . . . . . . . . . . . . ៥០

# TABLE DES MATIÈRES

Pages

1. Vidyudhammadesanā (Conférence faite à la Radio Phnôm-Penh), par le Vénérable Achar Nhoung-Sœung, membre de la Commission du Tripitaka........................ 1

2. Chbab-Srey (Conseils aux filles).......................... 14

3. Chbab Ariyasatthā (Conseils aux enfants).................. 26

4. Abrégé du Pañcatantra..................................... 31

5. Histoire de Rome. Extraits de divers documents de l'histoire universelle (suite).................................. 37

6. Géographie sommaire de l'Amérique du Sud................. 50

# វិទុរធម្មទេសនា កាណ្ឌ ទី ១០

## លោកអាចារ្យ ញ. សឿង ក្រុមជំនុំព្រះត្រៃបិដក

សំដែងក្នុងថ្ងៃព្រហស្បតិ៍ ៨ រោច ខែពិសាខ ឆ្នាំមមីចត្វាស័ក ព. ស. ២៤៩៥

(ត្រូវនឹងថ្ងៃ ៣ ខែម៉ែ ឆ្នាំ ១៩៤២)

## សុត្តសុទ្ធិកថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យដោយគោរព ។

វេលានេះ អាត្មាភាពនឹងសំដែងអំពីសេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធរបស់ពួកសត្វ ដើម្បីចែកជូនជាសាធារណប្រយោជន៍ចំពោះសាធុជនតាមលំអានពុទ្ធភាសិតយ៉ាងនេះថា:

កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ

ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា ។

សេចក្តីថា: សត្វទាំងឡាយរមែងបរិសុទ្ធដោយហេតុ ៥ ប្រការនេះ គឺ: កម្ម ១ វិជ្ជា ១ ធម៌ ១ សីល ១ ជីវិតដ៏ឧត្តម ១ មិនមែនបរិសុទ្ធព្រោះគោត្តឬព្រោះទ្រព្យឡើយ ។

ភាសិតនេះសំដែងថា សេចក្តីបរិសុទ្ធជាផលសម្រេចមកអំពីហេតុទាំង ៥ ប្រការនេះឯង ហើយសំដែងបដិសេធសេចក្តីបរិសុទ្ធដោយហេតុ

ដទៃ; វេលានេះសូមលើកយកហេតុទាំង ៥ ប្រការមកអធិប្បាយមួយម្ដងៗ តាមមាតិកាដែលទាក់ទងជាប់គ្នាជាលំដាប់ដូចតទៅនេះ:

១- កម្ម បានដល់ចេតនាគឺការតាំងចិត្ត ព្រោះជាតួធម៌ដែលបង្គាប់បញ្ជាប្រើឲ្យធ្វើឲ្យនិយាយឲ្យគិតសមដូចពុទ្ធភាសិតថា "ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ភិក្ខុទាំងឡាយ! តថាគតហៅចេតនាថាជាតួកម្ម" ។ បើតាំងចិត្តធ្វើនិយាយគិតប្រកបដោយ លោភៈ ទោសៈ មោហៈ ហៅថាបាបកម្ម (កម្មអាក្រក់) បើតាំងចិត្តសម្បយុត្តដោយមេត្តាករុណាវៀរចាកអកុសលមូលទាំង ៣ នោះហៅថាកុសលកម្ម (កម្មល្អ) កម្មទាំងពីរនេះរមែងហុចកំរៃផលឲ្យដល់អ្នកធ្វើផ្សេងៗគ្នា គឺបើធ្វើបាបកម្មត្រូវទទួលសេចក្ដីសៅហ្មង បើធ្វើកុសលកម្មត្រូវទទួលសេចក្ដីបរិសុទ្ធ សមដូចពុទ្ធភាសិតថា:

អត្តនាវ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនាវ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

សេចក្ដីថា: ធ្វើបាបខ្លួនឯង រមែងសៅហ្មងខ្លួនឯង មិនធ្វើបាបខ្លួនឯង រមែងស្អាតផូរផង់ខ្លួនឯង សេចក្ដីស្អាតនឹងមិនស្អាត ស្រេចតែនឹងខ្លួនឯង អ្នកដទៃជួយតែអ្នកដទៃឲ្យស្អាតបរិសុទ្ធមិនបានឡើយ ។ មានតែកម្មជាកុសល ទើបអាចធ្វើកាយវាចាចិត្តឲ្យស្អាតបាន គឺអាចធ្វើកាយឲ្យមាន

មារយាទរម្យទមរៀបរយ, ធ្វើវាចាឲ្យពីរោះសុភាពរាបសា, ធ្វើចិត្តឲ្យស្ងប់រម្ងាប់នឹងនួន ឥតមានអ្វីដទៃដែលអាចធ្វើខ្លួនឲ្យស្អាតប្រសើរជាជាង ការធ្វើល្អ និយាយត្រូវ គិតត្រូវនេះទៀតឡើយ; ទឹកប្រៀងផ្ទះដទៃ ៗអាចបំបាត់បានតែគ្រឿងស្មោកគ្រោកគឺមន្ទិលក្អែលខាងក្រៅប៉ុណ្ណោះ ចំណែកខាងកុសលកម្មអាចជម្រះលាងឲ្យស្អាត បានទាំងខាងក្នុងទាំងខាងក្រៅ ព្រោះហេតុនេះ ទើបលោកលើកយកកុសលកម្មថាជាហេតុនៃសេចក្ដីបរិសុទ្ធ ៗ ធម្មតាមនុស្សក្នុងលោក សុទ្ធតែត្រូវធ្វើ ត្រូវនិយាយ ត្រូវគិត, អំពើដែលសម្រេចមកអំពីការធ្វើ ការនិយាយ ការគិតទាំងនោះឯង ម៉ត់ចត់ស្អាតល្អបានដរាបទៅនោះ ត្រូវអាស្រ័យវិជ្ជាគឺការចេះដឹងជួយអែបនៃបគាំទ្រផង, ព្រោះអាស្រ័យហេតុនេះ ទើបលើកយកវិជ្ជាមកសំដែងជាលំដាប់ទី ២ ។

២– វិជ្ជា សេចក្ដីចេះដឹងច្បាស់ប្រាកដស្គាល់ហេតុផលនៃអំពើល្អនឹងអំពើអាក្រក់នោះៗឈ្មោះថាវិជ្ជា, គុណសម្បត្តិនេះ ជាបដិបក្ខទំនាស់គ្នានឹងអវិជ្ជាគឺសេចក្ដីល្ងង់ខ្លៅមិនចេះមិនដឹង; អវិជ្ជានេះ ជាតួមន្ទិលមួយដ៏ក្រៃលែងជាងមន្ទិលទាំងពួង រមែងរិតរួតរុំហ៊ុំបិទបាំងដួងចិត្តឲ្យងងឹតងងល់មិនឲ្យសត្វគិតយល់ដល់សេចក្ដីពិតៗ សមដូចពុទ្ធភាសិតថា "អវិជ្ជា បរមំ មលំ អវិជ្ជាជាមន្ទិលលេខ ១" លុះតែជនដែលមានវិជ្ជា ទើបអាចកំចាត់បង់ បន្សាត់ចាត់ចោលនូវមន្ទិលគឺអវិជ្ជានោះបាន ព្រោះវិជ្ជាគួរនា

ដូចជាពន្លឺដ៏រុងរឿង ដែលកំចាត់បង់នូវងងឹត ពុំនោះសោតដូចជាគ្រឿងអលង្ការសម្រាប់លើកកិត្តិយសមនុស្សឲ្យមានសិរីសួស្តីចំរើនរុងរឿង ប៉ុន្តែធម្មតាមនុស្សប្រសិនបើមានតែវិជ្ជាម្យ៉ាងហើយខ្វះធម៌សម្រាប់ជួយគាំទ្រផង ក៏ធ្វើខ្លួនឲ្យទៅជាបុគ្គលបរិសុទ្ធមិនកើត នឹងប្រែខ្លួនទៅជានាំបណ្តាលឲ្យបានសេចក្តីទុក្ខលំបាកទៅវិញ សេចក្តីនេះ សមគ្នានឹងពុទ្ធភាសិតថា :

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធមស្ស វិបាតយំ ។

សេចក្តីថា: ការចេះដឹងកើតឡើងដល់បុគ្គលពាលដើម្បីសេចក្តីវិនាសតែម្យ៉ាង (គឺថាធម្មតាបុគ្គលពាលចេះចំណេះវិជ្ជាណាមួយនាំបំផ្លាញតែខ្លួនឯង) វិជ្ជានោះរមែងសម្លាប់ចំណែកនៃកុសលរបស់បុគ្គលពាល ធ្វើប្រាជ្ញាឲ្យអន្តរាយខ្ចាត់ខ្ចាយខូចអសារឥតការ ។ សេចក្តីនេះបំភ្លឺឲ្យឃើញថា លុះណាតែមានធម៌ជួយជាកំឡាំងផង ទើបវិជ្ជាដើរទៅត្រង់មិនទីសទាសខុសឆ្វេង, ព្រោះហេតុនេះត្រូវលើកយកធម៌មកសំដែងជាលំដាប់ទី ៣ ។

៣ - ធម្មៈ សេចក្តីល្អ ដែលទ្រទ្រង់លើកស្ទួយអ្នកប្រព្រឹត្តមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់អាប់ឱនទន់ទាបឈ្មោះថាធម៌ក្នុងទីនេះ ធម៌នោះមានច្រើនប្រការ ប៉ុន្តែដែលនឹងលើកយកមកសំដែងក្នុងផ្លូវសេចក្តីនេះសំដៅយកហិរិឱត្តប្បៈ ។ សេចក្តីខ្មាសបាបខ្ពើមដែលលូតលាស់ផុះផុលផុះ

ចេញមកអំពីដួងចិត្តរបស់ខ្លួនឯងហើយ មិនហ៊ានប្រព្រឹត្តធ្វើអំពើទុច្ចរិត ដោយពិចារណាដល់ជាតិ ត្រកូល វ័យ សេចក្តីក្លៀវក្លាទាំងសេចក្តីចេះដឹងរបស់ខ្លួន, យ៉ាងនេះឈ្មោះថាហិរិ មិនមែនសំដៅយកត្រង់ដែលអៀនខ្មាសដល់អ្នកដទៃ ហើយមិនហ៊ានធ្វើបាបនោះឡើយ ។ ការដែលតក់ស្លុតខ្លាចរអារចំពោះទោសនៃអំពើទុច្ចរិត ហើយមិនហ៊ានប្រព្រឹត្តធ្វើអំពើទាំងនោះ ដោយពិចារណាឃើញភ័យ ៤ យ៉ាងគឺ ភ័យអំពីខ្លួនឯងតិះដៀលខ្លួនឯង ១ ភ័យអំពីអ្នកដទៃតិះដៀល ១ ភ័យអំពីរាជការដាក់អាជ្ញា ១ ភ័យអំពីការកើតក្នុងអបាយភូមិ ១ យ៉ាងនេះឯង ឈ្មោះថាឱត្តប្បៈ ។ ហិរិនិងឱត្តប្បៈទាំងពីរនេះជាគុណនៃគ្នា ព្រះវិជិតមារទ្រង់ត្រាស់ហៅថាធម៌ស ព្រោះជាធម៌អាចញ៉ាំងបុគ្គលអ្នករក្សាឬអ្នកកាន់តាមឲ្យសបរិសុទ្ធផូរផង់; បុគ្គលក្នុងលោកលុះណាតែមានធម៌ទាំងពីរនេះជិតជាប់នៅក្នុងខន្ធសន្តាន ទើបអាចប្រព្រឹត្តធម៌ដទៃៗ ឲ្យផូរផង់ ប្រៀបដូចជាសំពត់ដែលស្អាត ប្រាសចាកក្អែល រមែងទទួលស្រូបយកទឹកជ្រលក់គ្រប់ពណ៌តាមបំណងអ្នកជ្រលក់ដូច្នោះឯង ។ ហិរិនិងឱត្តប្បៈនេះ មានក្នុងសន្តានរបស់ជនណា ជននោះរមែងជាអ្នកមានសីល ហើយអាចដុសខាត់សីលនោះឲ្យស្អាត, រក្សាការពារឃុំគ្រងមិនឲ្យដាច់ធ្លុះធ្លាយពព្រុះពពាលថែមទៀត, ព្រោះហេតុនេះ ត្រូវលើកយកសីលមកសំដែងជាលំដាប់ទី ៤ ។

៨– សីល ការគ្រងកាយវាចាឲ្យស្ងប់ស្ងៀមរម្យទមរៀបរយ ហាមសេចក្ដីប្រព្រឹត្តិប្រឡូសបើសល្មើសខុសគន្លងមិនឲ្យកើតឡើងឈ្មោះថាសីលៗ នេះបើបុគ្គលគ្រងឲ្យផូរផង់ហើយ រមែងការពារកំងវិប្បដិសារៈ (សេចក្ដីក្ដៅក្រហាយស្ដាយក្រោយ) មិនឲ្យកើតក្នុងសន្ដាន ហើយអាចទប់ក្រសោបប្រមូលនាំយកសេចក្ដីបរិសុទ្ធឬសេចក្ដីសុខមកឲ្យអ្នកគ្រងបានតាមបំណង ។ កាលបើមានសីលហើយ រមែងរកស៊ីចិញ្ចឹមជីវិតតាមផ្លូវសុចរិតមិនបៀតបៀនសត្វដទៃ ព្រោះតែជីវិតរបស់ខ្លួន ព្រោះហេតុនេះ ត្រូវលើកយកជីវិតដ៏ឧត្ដមមកសំដែងជាលំដាប់ទី ៩ ។

៩– ជីវិតដ៏ឧត្ដម សេចក្ដីចៀសវាងជំនួញមិនគួរជួញ ៥ ប្រការ និងអំពើទុច្ចរិតផ្សេងៗ មានការឆបោក បំបាត់បំភាន់បជាន់យកសម្បត្តិអ្នកដទៃជាដើម ហើយប្រកបការងារចិញ្ចឹមជីវិតតាមផ្លូវត្រូវមានកសិកម្ម (ការធ្វើស្រែចំការ) និងវាណិជ្ជកម្ម (ការជួញប្រែ) ជាដើម, យ៉ាងនេះឯងហៅថាជីវិតដ៏ឧត្ដម ព្រោះជីវិតដែលរស់នៅដោយសារសម្បត្តិដែលគេបានមកតាមផ្លូវសុចរិតនោះ ជាជីវិតត្រជាក់ត្រជុំមិនក្ដៅក្រហាយ ។ កាលបើមានជីវិតបរិសុទ្ធហើយ ទោះបីយកសម្បត្តិទាំងនោះទៅចាយវាយ ឬយកប្រយោជន៍បច្ចុប្បន្ននិងប្រយោជន៍បរលោកឲ្យបានពេញកើនលើសជាងធម្មតាទៅទៀត ក៏អាចសម្រេចសមតាមប្រាថ្នា, ប្រយោជន៍ដែលបានមកនោះទៀតសោតក៏ឈ្មោះថាជាប្រយោជន៍បរិសុទ្ធ

ព្រោះហេតុនេះ ទើបព្រះសុគតទ្រង់ត្រាស់លើកយកជីវិតដ៏ឧត្តមមក សំដែងថាជាហេតុនៃសេចក្ដីបរិសុទ្ធ ។ គុណធម៌ទាំង ៤ ប្រការដែលសំដែងមកនេះ ជាហេដ្ឋិមបរិយាយ (ថ្នាក់ក្រោម) បើពោលដោយឧបរិមបរិយាយ (ថ្នាក់លើ) វិញនោះយ៉ាងនេះគឺៈ កម្មបានដល់ការតាំងចិត្តបំពេញអដ្ឋង្គិកមគ្គ (ផ្លូវប្រកបដោយអង្គ ៨), វិជ្ជា បានដល់សម្មាទិដ្ឋិ (សេចក្ដីយល់ត្រូវ) នឹងសម្មាសង្កប្បៈ (សេចក្ដីត្រិះរិះត្រូវ), ធម៌ បានដល់សម្មាវាយាមៈ (សេចក្ដីខំប្រឹងត្រូវ) សម្មាសតិ (សេចក្ដីរលឹកត្រូវ) នឹងសម្មាសមាធិ (សេចក្ដីដំកល់ចិត្តឲ្យនឹងនួនត្រូវ), សីល បានដល់សម្មាវាចា (សំដីត្រូវ) នឹង សម្មាកម្មន្តៈ (ការងារត្រូវ), ជីវិតដ៏ឧត្តមបានដល់សម្មាអាជីវៈ (សេចក្ដីចិញ្ចឹមជីវិតត្រូវ) ។ អ្នកដែលដើរតាមផ្លូវទាំង ៨ នេះ រមែងធ្វើខ្លួនឲ្យបរិសុទ្ធតាមថ្នាក់តាមជាន់រហូតទៅទល់ភ្នានឹងប្រានភាពបុថុជ្ជនចោលហើយឡើងទៅកាន់អរិយភាពបាន, យ៉ាងនេះឯងឈ្មោះថាជាអ្នកបរិសុទ្ធដ៏ឧក្រិដ្ឋ ។ សេចក្ដីដែលសំដែងមកទាំងអស់នេះបំភ្លឺឲ្យឃើញជាក់លាក់ថា ពួកសត្វ លុះណាតែមានគុណធម៌ទាំង ៤ យ៉ាងនេះ ទើបអាចធ្វើខ្លួនឲ្យបរិសុទ្ធមិនមែនបរិសុទ្ធព្រោះគោត្តវង្សត្រកូលសែស្រឡាយ ឬព្រោះទ្រព្យសម្បត្តិឡើយ ព្រោះថាធម្មតាបុគ្គលគ្រប់រូប សូម្បីមានវង្សត្រកូលខ្ពង់ខ្ពស់ ព្រមទាំងបរិបូណ៌ដោយធនធានស្ដុកស្ដម្ភមាំមួនច្រើនពោរពាសយ៉ាងណាក៏ដោយ ប៉ុន្តែបើខ្វះធម៌ទាំង ៤ ប្រការនេះហើយ

វង្សត្រកូលនឹងកោតសម្បូរទាំងទោះនឹងកាប់ខ្នងទន់ទាបស្រកស្រុតរលស់ សាបសូន្យទៅជាលំដាប់កុំខាន, កាលបើគោត្រត្រកូលនឹងសម្បត្តិវិនាសហើយ ប្រយោជន៍ដែលសម្រាប់ធ្វើខ្លួនឲ្យបរិសុទ្ធផូរផង់ ក៏សម្រេចដល់បុគ្គលនោះមិនបានដែរ ។ ម្យ៉ាងទៀត មិនមែនបរិសុទ្ធឬមានសិរីសួស្តីឥតសិរីសួស្តីព្រោះឈ្មោះល្អឬឈ្មោះអាក្រក់ឡើយ; មានពួកជនខ្លះយល់ថាជោគជ័យកើតមកអំពីឈ្មោះពីរោះសមល្អ បានជាក្នុងពេលដែលបានបុត្រាបុត្រីវេលាណា គេច្រើនតែរើសរកឈ្មោះដែលពីរោះៗ មកដាក់ឲ្យបុត្រាបុត្រីទាំងនោះ ដើម្បីនឹងធ្វើសិរីសួស្តីឲ្យកើត: ត្រង់ដែលរើសយកឈ្មោះល្អសមរម្យមកដាក់ឲ្យបុត្រាបុត្រីនោះ ជាការប្រពៃណាស់ហើយ ដើម្បីនឹងនាំឲ្យពីរោះដល់ត្រចៀកអ្នកផង ឬដើម្បីនឹងឲ្យងាយហៅស្រួលមាត់ មិនជាការទាស់ខុសអ្វីទេ ប៉ុន្តែសូមកុំយល់ថាជោគជ័យសម្រេចមកអំពីឈ្មោះល្អ ការឥតជោគជ័យកើតមកអំពីឈ្មោះអាក្រក់នោះឡើយ ព្រោះសេចក្តីយល់នេះទំនាស់នឹងពុទ្ធភាសិតខាងដើម ។ សូមលើកយករឿង ១ មកសំដែងបំភ្លឺសេចក្តីនេះឲ្យឃើញច្បាស់លាស់ដូចតទៅនេះ ។

ក្នុងកាលដ៏កន្លងទៅហើយ ព្រះបរមពោធិសត្វនៃយើងកើតក្នុងត្រកូល ១ ទ្រង់សិក្សាវិជ្ជាសាស្ត្រចេះចប់សព្វគ្រប់បានឡើងថ្នាក់ជាអាចារ្យទិសាបាមោក្ខ បង្ហាត់បង្រៀនមាណពច្រើនរូបនៅសាលា-វិទ្យាល័យក្នុងក្រុងតក្កសិលា ។ បណ្តាមាណពជាសិស្សទាំងនោះមាន

ខាណពម្នាក់ឈ្មោះ "គំរក់(១)" មាណពទាំងអស់គ្នា តែងហៅថា ចៅគំរក់ៗ ដូច្នេះជាធម្មតា ។ ថ្ងៃ១ មាណពនោះមានសេចក្ដីត្រិះរិះថា ឈ្មោះអាត្មាអញនេះអពមង្គលធំណាស់ បើដូច្នោះគួរអាត្មាអញនឹងចូលទៅសុំឲ្យអាចារ្យទិសាបាមោក្ខរកឈ្មោះដែលជាមង្គលមានជោគជ័យមកផ្លាស់ជំនួសវិញ, លុះគិតរួចហើយទើបចូលទៅសារស័ព្ទដំរាបអាចារ្យតាមសេចក្ដីយល់របស់ខ្លួន, អាចារ្យទិសាបាមោក្ខក៏តបមកវិញថា អញមិនដឹងជារកឈ្មោះណាមកផ្លាស់ដាក់ឲ្យត្រូវចិត្តឯង ទេ បើដូច្នោះចូរឯងដើរទៅសួរស្វែងរកឈ្មោះណាដែលខ្លួនពេញចិត្ត ហើយនាំយកមកប្រាប់អញនឹងផ្លាស់ឲ្យ ។ ចៅគំរក់បានស្ដាប់ហើយក៏រៀបចំស្បៀងអាហារបង្ការតាមផ្លូវ សំពះលាអាចារ្យចេញពីក្រុងតក្កសិលា ឆ្ពោះទៅកាន់ស្រុកដទៃដើម្បីនឹងស្វែងរកឈ្មោះជាមង្គល, លុះដើរទៅដល់ភូមិ ១ បានឃើញជនច្រើនមីរដេរដាស កំពុងតែសែងខ្មោចយកទៅដុត ចៅគំរក់ ក៏សួរថា អ្នកដែលស្លាប់នេះឈ្មោះអ្វី?

— ឈ្មោះរស់(២) ។

— បើឈ្មោះរស់ដូចម្ដេចក៏ស្លាប់?

— ទេ! ល្ងង់អ្វីក៏ល្ងង់ម៉្លេះ ដូចជាគ្មានដឹង ១០ សោះហើយនេះ,

---

១ បាលី បាបកៈ ។ ២ បាលី ជីវកៈ ។

ទោះបើឈ្មោះរស់ក៏ដោយ ឈ្មោះស្លាប់ក៏ដោយ តែបើដល់កំណត់ត្រូវស្លាប់ហើយ គង់តែស្លាប់ដូចគ្នាទេ, ឯឈ្មោះនោះគ្រាន់តែជាឈ្មោះសម្រាប់ហៅប៉ុណ្ណោះទេតើ មិនមែនគ្រាន់តែឈ្មោះរស់ហើយរស់រហូតលែងស្លាប់នោះកាលណា ។ ចៅតំរែក៏បានស្ដាប់ជាក់ក៏នឿយណាយសោយចិត្តគង់ឈ្មោះល្អឈ្មោះអាក្រក់ ដោយគិតឃើញថាឈ្មោះនេះយកជាប្រមាណមិនបាន ហើយទើបត្រឡប់វិលមកក្រុងតក្កសិលាវិញ, លុះដើរមកដល់ផ្សារ ១ បានឃើញចៅហ្វាយនាយកំពុងតែចងខ្ញុំស្រីម្នាក់ហើយវាយដំប្រដាក់ស្ដីបន្ទោសដោយពាក្យទ្រគោះផ្សេងៗ, ចៅតំរែក៏ដើរសសៀរចូលទៅជិតហើយសួរថា សូមលោកអត់ទោស, ចុះនាងនេះត្រូវជាអ្វីនឹងលោក ហើយហេតុដូចម្ដេចក៏វាយដំគ្នាខ្លាំងម្ល៉េះ?

— នាងនេះត្រូវជាខ្ញុំស្រីរបស់យើង បានជាយើងវាយយ៉ាងនេះព្រោះវាខ្ជិលធ្វើការងារ ។

— នាងនេះឈ្មោះអ្វី?

— ឈ្មោះនាង "រក្សាសម្បត្តិ [១]"

— បើឈ្មោះនាងរក្សាសម្បត្តិ ហេតុដូចម្ដេច ក៏ក្រីក្រនៅខ្ញុំគេដូច្នេះ?

— យីអើ! ព្រើលអ្នកព្រើលម្ល៉េះ បើកុំតែមានដើមចេញចូលទីនេះនិយាយ កុំអីគាមោងស្អុះហើយគាត់ទេះ, ប្រយោជន៍អ្វី ដោយឈ្មោះនោះ

១ បាលី: ធនបាលី ។

ទោះបីឈ្មោះរក្សាសម្បត្តិក៏ ឈ្មោះបំផ្លាញសម្បត្តិក៏តែត្រូវក្រីក្រហើយ គង់តែក្រីក្រដូចគ្នាទាំងអស់ទេ, ការមានហើយនឹងក្រីក្រមិនមែនសម្រេចមកអំពីឈ្មោះនេះឡើយ ។

មាណពបាទស្តាប់ហើយ កាន់តែសោយចិត្តជាងមុន ក៏ដើរចេញអំពីផ្សារនោះមកទៀត, លុះមកដល់ពាក់កណ្តាលផ្លូវបានជួបនឹងបុរសម្នាក់កំពុងតែវង្វេងផ្លូវដើររើមរាមៗ ចុះឡើងៗ ទើបសួរថា:

– អ្នកឯងដើររកអ្វីរើមរាមៗ ដូច្នេះ?

– ខ្ញុំវង្វេងផ្លូវទេតើ ។

– ចុះអ្នកឯងឈ្មោះអ្វី ?

– ខ្ញុំឈ្មោះ “ចៅស្គាល់ផ្លូវ[១]”

បើឈ្មោះចៅស្គាល់ផ្លូវ ហេតុដូចម្តេចក៏វង្វេងផ្លូវទៅវិញ ?

– ទេ! ផ្តាសៗ! ដង្ហើមមូលស្ទុះហើយអ្នកនេះ, អ្នកឯងមកពីស្រុកណាមកហ្នឹង? ទោះបីឈ្មោះស្គាល់ផ្លូវក៏ដោយ វង្វេងផ្លូវក៏ដោយ, តែបើវាត្រូវនឹងវង្វេងហើយ គង់តែវង្វេងដូចគ្នាទាំងអស់, មិនមែនគ្រាន់តែខ្លួនឈ្មោះស្គាល់ផ្លូវហើយមិនវង្វេងផ្លូវនោះទេ, យកឈ្មោះមកជាប្រមាណដូចម្តេចកើត ? ឈ្មោះនេះគេគ្រាន់តែដាក់មកឲ្យពីរោះត្រចៀកឬឲ្យងាយចំណាំ ងាយស្គាល់ ងាយហៅតែប៉ុណ្ណោះទេតើ ។

---

១ បន្ទក: ។

មាណពបានស្តាប់ពាក្យនោះហើយក៏រឹងរឹតតែក្ដៅប្រាស់នឿយណាយសោយចិត្ត លែងនឹកទោមនស្សនឹងឈ្មោះរបស់ខ្លួន ដើរចូលមកកាន់ក្រុងតក្កសិលាវិញ ហើយចូលទៅកាន់សំណាក់អាចារ្យទិសាបាមោក្ខៗក៏សួរថាដូចម្ដេចទៅ:ចៅគំរក់, ឯងរកឈ្មោះជាមង្គលបានហើយឬនៅ? មាណពក៏ជំរាបតាមរឿងរ៉ាវដែលខ្លួនបានជួបប្រទះថា: បាទទេ, ដូចជាដូចទេ លោកគ្រូ រឿងនេះ ឈ្មោះរស់ក៏ស្លាប់, ឈ្មោះនាងកេក្រសម្បត្តិក៏ក្រីក្រ, ឈ្មោះចៅស្គាល់ផ្លូវក៏វង្វេងផ្លូវ, ណ្ហើយចុះខ្ញុំបាទសុខចិត្តយកឈ្មោះចៅគំរក់ចាស់ដដែលនោះវិញ មិនបាច់ផ្លាស់ប្ដូរទេ ព្រោះមិនមែនមានសិរីសួស្ដីឬកឥតសិរីសួស្ដីអ្វីមកអំពីឈ្មោះល្អឬអាក្រក់នោះឡើយ ។ អាចារ្យទិសាបាមោក្ខក៏និយាយបំភ្លឺថែមទៀត ហើយពោលគាថាយ៉ាងនេះថា :

ជីវកញ្ច មតំ ទិស្វា ធនបាលិញ្ច ទុគ្គតំ
បន្ថកញ្ច វនេ មូឡ្ហំ បាបកោ បុនរាគតោ ។

សេចក្តីថា: មាណពឈ្មោះគំរក់ដើរទៅស្វះស្វែងរកឈ្មោះជាមង្គលបានឃើញបុរសឈ្មោះរស់ក៏ស្លាប់, ឃើញស្ត្រីឈ្មោះនាងកេក្រសម្បត្តិក៏ក្រីក្រ ឃើញបុរសឈ្មោះចៅស្គាល់ផ្លូវក៏វង្វេងក្នុងព្រៃ ឥឡូវនេះ ត្រឡប់មកវិញហើយ ។

រឿងដែលសំដែងមកនេះ ដើម្បីបញ្ជាក់ឲ្យឃើញជាក់លាក់ថា សេចក្តីបរិសុទ្ធនឹងមិនបរិសុទ្ធមិនមែនសម្រេចមកអំពីឈ្មោះល្អ ឬឈ្មោះអាក្រក់

នោះឡើយ, ត្រង់ដែលបរិសុទ្ធស្រេចតែនឹងមានគុណធម៌ទាំង ៥ យ៉ាង ដែលមិនបរិសុទ្ធមកអំពីខ្វះធម៌ទាំងនោះ ដូចពោលមកហើយខាងដើម ។

អាត្មាភាពសំដែងអំពីសេចក្តីបរិសុទ្ធនឹងមិនបរិសុទ្ធរបស់ពួកសត្វ ក៏សន្មតថា ចប់ដោយសង្ខេបល្មមសមគួរដល់កាលវេលា ។

ធម្មទេសនានុភាវេន សុខិតា ហោន្តុ ចាណិនោ

ក្ខីសុ អត្ថេសុ តិដ្ឋន្តុ សហ សព្វេហិ ញាតិភិ ។

ដោយអានុភាពនៃធម្មទេសនា (នេះ) សូមឲ្យសត្វទាំងឡាយបានសេចក្តីសុខសាន្តត្រាណ សូមឲ្យបានសម្រេចប្រយោជន៍ទាំងពីរយ៉ាង (គឺប្រយោជន៍បច្ចុប្បន្ននឹងប្រយោជន៍បរលោក) ព្រមទាំងពួកញាតិសាច់សាលោហិតទាំងអស់គ្នា កុំបីឃ្លាតឡើយ ។

ចប់វិទ្យុធម្មទេសនា កណ្ឌទី ១០ តែប៉ុណ្ណេះ ។

# ច្បាប់ស្រី

## បទភុជង្គលីលា

នេះបទកំណត់ចងជា ភុជង្គលីលា ចងជាច្បាប់ស្រី ។ កាល-នាងឥន្ទ្រទេវី បរចាកតាមប្តី គឺបណកយក្ស ។ នាងវិមលាជាមាតា បើកបន្ទូលថា ហៃកូនពិសី ។ នាងនឹងត្រាច់ត្រង់តាមប្តី ចេញចាកអំពី ពិភពនាគនេះ ។ ទៅស្ថានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បំរើស្វាមី ។ ផ្ចើតត្តប្រតិបត្តិប្រក្រតី កុំឲ្យស្វាមី អាក់អន់ចិន្តា ។ នាងអើយគម្លែងក្រឡា ជាម្ចាស់សិរសា កូនកុំមាក់ង៉ាយ ។ ហៃកូនស្រីស្ងួនមាសម្ដាយ ក្រណាស់នាងអាយ តាមដោយច្បាប់ស្រី ។ ក្រមួយមិនបានសំដី ពាក្យទន់តិចនៃ ឲ្យញាតិចូលចិត្ត ។ ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងធំស្វា ។ ទោះមានមិនមានក្តីណា ពាក្យផ្អែមបរចា ទើបគេស្រឡាញ់ ។ កុំដូចិត្តស្វកំណាញ់ មិនមានអស់អញ នឹងញាតិសន្តាន ។ កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី ។ ទោះនឹងនិយាយស្រដី ការកើតជាស្រី កុំស្តីលេះលោះ ។ ជាលេងដូចក្មេងញ៉ោះញ៉ោះ ឃើញប្រុសកំឡោះ សសៀរចូលជិត ។ ហើយព្រៀងបញ្ជៀងមិនគិត ប្រុសព្រើលបានចិត្ត ចាហានះដាយសារ ។ ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទកុងខូច ។

សើរើពុំធ្វើទឹងទ្ទូន ស្រដីមិនមូល មិនមានអៀនអន់ ។ ឃើញគេបៀត
បែរគេយកគន់ សើចសួរចំអន់ ចំអកឲ្យប្រុស ។ ហៅស្រីអប្រិយទុរយស
មិនខ្លាចខ្លួនខុស មារយាទគ្រិតគ្រែម ។ ធ្វើការអន្ទុយប្រចាំ នឹងសម
ពុំសម ផ្កាឯងជាស្រី ។ មិនកោតមិនខ្លាចចិត្តប្តី ឲ្យប្រុសដទៃ មាក់
ងាយប្តីណា ។ ហៅស្រីឥតលក្ខណា ឥតមានកិរិយា មារយាទពុំសម ។
ធ្វើការផងណាប្រើចំ តោះត្បាញចាក់ដំ នាំខំឲ្យហើយ ។ កុំទុក
ទៅមុខទៀតឡើយ ថាចាំបង្ហើយ កម្រណាសណា ។ តោះធ្វើ
ហូលតោមព្រែផ្កា ដាក់ត្បាញហើយណា បានស្រេចសមធ្វើ ។ ធ្វើ
ឲ្យកើតកេរ្តិ៍ប្រសើរ ហើយកុំឲ្យដើរ លេងផ្ទះគេណា ។ ឲ្យស្ងួន
ខិមខ្លួនរក្សា នាំខំធ្វើការ ទានខ្លួនក្រមុំ ។ មានប្តីបានអ្វីជាខំ
រវល់កូនយំ កម្របេះធៀត ។ ព្រួយចិត្តគិតបង្អៀត មួយហើយ
មួយទៀត យំទារតែធំ ។ រង់ព្រួយទាំងមួយទាំងពីរ រកបានឲ្យធំ
ទើបបានបាត់មាត់ ។ តោះការការធ្វើឲ្យស្អាត ហូលគោមគាតកាត់
អន្ទូងត្បាញទៅ ។ កុំទុកកង់ស្រគស្ញាទៅ ក្រែងដល់យូរទៅ ខាត
ខ្លួបអសារ ។ ហៃកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី ។
ចូររករៀនយកច្បាប់ស្រី ឲ្យកោតខ្លាចប្តី គម្ពែងក្រឡា ។ ធ្វើវត្តប្រតិ-
បត្តិសោតណា ឲ្យនាំរក្សា ក្នុងក្អេងទាំងបី ។ ឲ្យកាត់ឲ្យគង់ប្រក្រតី

សព្វថ្ងៃកុំបី ភ្លេចផ្ដាំឲ្យនេះ ៗ ក្រែងកលដូចផាលព្រាយប្រេះ កើតក្ដៅ

រលេះ រលាកអស់អង្គ ៗ ភ្លើងក្រៅកុំនាំទៅក្នុង ឲ្យឆេះបំផ្លុង រំផ្លុំ

បង្កាត់ ៗ ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឲ្យឆេះឯក្រៅ ៗ ស៊ុជ

អាលបណ្ដាលឲ្យក្ដៅ ដាលដល់ក្នុងទៅ អសោចអប្រិយ ៗ ឲ្យនាងចាំ

ប្រុងស្មារតី មើលភ្លើងទាំងបី រក្សាឲ្យគង់ ៗ ភ្លើងនោះឲ្យគុណពុំលង់

នឹងឲ្យឧដុង ឧត្ដមគន្ធង ៗ កើតយសរបស់ទ្រព្យផង បរិបូណ៌ឥតហ្មង

ប្រសើរក្ដាត់ណា ៗ ភ្លើងមួយនោះឲ្យរក្សា គឺគុណមាតា បិតាស្ងួន

គ្រង ៗ ឲ្យនាងធ្វើដោយគន្ធង ប្រណិប័តន៍កុំធ្គង នឹងម្ដាយឪពុក ៗ

ឲ្យចាំថែទាំ ញ៉ិកញ៉ុក បំណិបំណុក បំណង់អាត្មា ៗ កុំឃ្លានទុកចំឡើយ

ណា ឆ្ងាញ់ឈ្ងុយពិសា ជូនជាប្រក្រតី ៗ ពាក្យពេចន៍ការកិច្ចអ្វីៗ

អត់ធ្មត់កុំបី ឲ្យអាក់ចិន្ដា ៗ ភ្លើងមួយគង្អែងក្រឡា គឺប្ដីអាត្មា បិតរថេរ

រួមរក្ស ៗ ឲ្យនាងប្រណិប័តន៍ជៀងជាក់ កុំធ្វើឲ្យអាក់ ឲ្យអន់ចិត្ត

ប្ដី ៗ អត់ធ្មត់ខ្ជាប់ខ្ជួនជ្រាតស្រី កុំឲ្យស្រដី ទុកគេជាស្មើ ៗ ទោះ

កើតហេតុកេទសារពើ ពាក្យពុំប្រសើរ ជញ្ជីងចាំស្ដាប់ ៗ ទោះប្ដី

ស្រដីពុំគាប់ ពុំគួរឲ្យប្រាប់ បានដឹងដល់ម្ដាយ ៗ កើតទំនង់រង់ខ្វរខ្វាយ

ក្នុងពាក្យពីម្ដាយ ខ្សឹបខ្សៀវប្រាប់ប្ដី ៗ មិនក្សាន្តបែកបានពីរបី កើត

ជាសំដី សួរចុះសួរឡើង ៗ ពុំស្ងាត់ស្ងៀមបាត់បង់ ជជែកនាំ

ឡើង ចចើងមិនបាត់ ៗ តតាំងពាក្យខ្លាំងមិនស្ងាត់ មិនស្ងៀមឲ្យបាត់

ឲ្យបានទីសុខ ៗ ដផែកស្មើរបែកទាំងស្រុក មិនមានហៅសុខ យូរលង់
ទៀយនៃ ៗ នេះហៅក្នក់ក្ដើងទាំងបី ម្ដាយផ្ដាំកូនស្រី ឲ្យចាំរក្សា ៗ
នាងអើយគម្ដែងក្រឡា ខំសង្គងម្ដេចម្ដា ម្ដាយផ្ដាំកូនស្រី ៗ ឲ្យអត់
សង្កត់ហ្ឫទ័យ កូនកុំស្រដី ដើម្បីកំបាំង ៗ កុំដេរកុំចេញផ្សាខ្ចាំង
ខ្សត់ខ្សោយខ្មៅខ្មាំង នាងកុំមើលងាយ ៗ ល្ងង់ខ្សោយប្រើឲ្យនិយាយ
ណែនាំលេងលាយ ឲ្យស្រួលពល ៗ ទោះប្ដីស្រដីម្ដេចម្ដា ខេរខឹង
ដេរថា ប្រោះពាក្យទម្ងន់ ៗ ក្រោធក្រេវឆ្មុលឆៅមិនអន់ មិនអាក់ស្រាក
ស្រន្ត ដោយចិត្តគាន់គាញ់ ៗ ខ្ញូរខាំខ្ញេញ ដេរថាជន្ទេញ ផ្សិត
ទាស់ទើងចិត្ត ៗ ឲ្យកូនស្រីស្ងួនខំអត់ ឲ្យបានរលត់ រលាយកំហឹង ៗ
កុំកូនកាន់ខ្លួនប្រែប្រឹង តតបទៅទឹង អកដាស្វាមី ៗ ខេរខឹងក្រញ៉ឹង
សំដី មិនគិតខ្លួនស្រី ស្រដីទ្រគោះ ៗ ប្រកែកសម្ដីពាក្យគំរោះ គំរាម
បញ្ឆោះ បញ្ឆោរឲ្យខឹង ៗ រឹងរូសមើលមុខសំឡឹង សំឡក់ទៅរឹង
បងើងនាំឈ្លោះ ៗ រឹងទ្ទឹងឆ្លើយពាក្យបញ្ឆោះ បំបែកផ្លាឈ្លោះ បំបែរ
ពុំទៀង ៗ ដេរថាផ្ទៃឆ្លាបំព្រៀង ដៀលត្មះបញ្ឈៀង បញ្ឈឺចិត្តប្ដី ៗ
ប្ដោកប្ដោះប្រទះអឺៗ តាប់តាលទៅដី បែកបាក់ពុំគិត ៗ មិនស្រួល
ទទួលបាត់មាត់ ម្នះម្នេញកងចិត្ត ឲ្យបានប្ដីតាញ់ ៗ ទើបបានសុខចិត្ត
ជាវិញ ហៅស្រីម្នះម្នេញ អប្បគេរ៍យសន្ដាយ ៗ ហៃកូនស្រីស្ងួន
មាសម្ដាយ ខុសណាស់នាងកាយ កុំធ្វើដូចគេ ៗ ទោះបីប្ដីនាងដេរ

នាងចូលទៅឯ ដំណេកគិតស្រន ៗ ចេញមកនាងបើកពាក្យទន់ ស្រដី
ឲ្យអន់ស្រាយទោសនោះទៅ ៗ ទោះបីប្ដីប្រដៅ ចូរនាងចាំនៅ ទុក
កងអាត្មា ៗ ពាក្យពេចន៍កុំភ្លេចឡើយណា ក្រែងធ្គងមេបម្ដា ដ្បិតបាន
ផ្ដាំស្រាប់ ៗ ព្រោះឯងមិនក្រែងមិនស្ដាប់ ពាក្យគេបង្គាប់ បង្កើតតែ
ឈ្មោះ ៗ ឥតសុខអាក្រក់តែឈ្មោះ ពុតតែប្រពោះ មិនចេះហៅល្ហ ៗ
នេះពុំគប់ជាស្រីទេ ជាអ្នកប៉ោឡៃ ចិត្តចោរដកចង ៗ ឲ្យមាត់បង្គ្រិប
ប្ដីផង ឲ្យគេស្ដាប់ហោង ថាឯងគ្រាន់បើ ៗ គឺមោះនាងនោះមិនប្រើ មិន
បើកឲ្យដើរ បពញ្ចូឲ្យទេ ៗ ទោះបើប្ដីប្រើមាសមេ កុំកូនចំអែ ចំអៀកមិន
ទៅ ៗ ផ្លាយផិតកុំគិតរង់នៅ ក្រោកក្រេសដើរទៅ កុំឲ្យប្ដីដើរ ៗ កុំទៅ
យូរនៅផ្ទះគេ រវល់ទំនេរ រវៀសមកណា ៗ នុកូនខ្ញុំមខ្លួនមាតា ជាស្រី
នេះណា កម្រែណាស់នាង ៗ មិនថាផ្សិតល្អរូបរាង មិនរើសផ្សិតជាង
ចេះការទាំងគ្រប់ ៗ មិនបានស្គាល់ទីគោរព ស្គាល់តែឧបទ្រព ទាំងជប់
ប្រការ ៗ ហៅតែទ្រង់ល្អរូបា ពិតហើយចេះការ គួរគោតដោយយ៉ាង ៗ
មួយល្អរូបស្រឡាង ឥតគេដូមទាង ច្បាប់ជងមិនចេះ ៗ ល្អពិតគំនិត
មិនផេះ ទោះខ្ញៅក្រផេះ ការសោតសមគួរ ៗ គឺមោះនាងនោះមិនជួ
ចេះដឹងសមគួរ ស្គាល់អស់ភរិយា ៗ នេះឯងពីព្រេងលោកថា ហៅល្អ
រូបា គបកល្យាណ៍ ៗ ហៃកូនស្រីសួនពិសី ម្ដាយប្រាប់អំពី ឧបទ្រព
ចង្រៃ ៗ កាន់ក្បាលប្ដីហើយរកថៃ មិនបាទលើកដៃ ពីរទូលសំពះ ៗ

លោកទុកស្មើកុកទំផុះ រង្គុំរង្គុះ ទីងបង់អស់ទ្រព្យ ។ កន្ទុងជើងប្ដីពុំគាប់
ព្រោះចិត្តចង់ឆាប់ រលងជើងប្ដី ។ ស្មើសត្វលលកខ្មោចខ្ចី ហើរព្រាស់
អព្រិយ កើតព្យាធិរោគា ។ ចង្រៃមួយនៃពលគ្នា ចេញចូលមាត់ទ្វារ
ពុំបានបិទបាំង ។ ធ្វេសប្រាណខុសខាននមិនរាំង មិនរុញបំបាំង មើល
យល់សាយសុះ ។ ទុកស្មើគេអុជបន្ទុះ ឲ្យបោរចូលចុះ យកទ្រព្យទាំង-
ឡាយ ។ ស្រីមួយសើចលេងក្អាកក្អាយ ពុះលេចចម្ងាយ រលង់ផ្ទះបី ។
ស្មើសត្វចតាតបក្សី ចូលភូមិផងក្ដី ចង្រៃក្ដាត់ណា ។ ស្រីមួយដេកដាក់
កាយា ប្រះប្រែអាត្មា ឲ្យខ្លួនទៅប្ដី ។ ទុកស្មើពស់ក្រាយអព្រិយ
ឡើងផ្ទះឥតបី ឥតបើគណនា ។ ចង្រៃកាចក្រៃពុំជា ទីងព្រាត់ប្រាស
គ្នា ពុំបានវែងឆ្ងាយ ។ ស្រីមួយសក់វែងអន្ទាយ រសុះរសាយ សក់
សោតរេព ។ នៅមាត់អណ្ដូងមាត់ទ្វារ បីដូចមដ្ឋាក ឆ្មាលាក់ក្រចក ។
ចង្រៃឥតបីបើរក រេពសំកក មិនចុកសក់ង៉ាយ ។ ស្រីមួយដើរទៅ
ទាត់ដាយ ព្រលាន់ស្មើរធ្លាយ ប្រែបពីសន្ទឹក ។ សំពត់ដាចដាចមិនគិត
ដើរព្រគតឹក ស្មើស្ទូរន្ទុះ ។ ញាំញើដំណើរលេលះ ដាក់ជើងលើផ្ទះ
គគ្រាគគ្រែង ។ កក្រើកផ្ទះទាំងបីល្វែង ដូចកលគេសែង របស់ចេញ
ទៅ ។ ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្ទុងហួសទៅ មិនចាប់ចេញទុក ។
ពុំថេរចំណេររទៅមុខ ពុំបេះដាក់ទុក ពាយពលតែល្វែង ។ ទ្រព្យនោះ
រលស់ចេញឯង ចង្រៃតាស់តែង ធ្វើឲ្យអន្តរាយ ។ តោះធំចំណីទូវបាយ

លបលួកកាយ ពមពុំសណ្ដាប់ ៗ កូនអើយនេះហើយចូរស្ដាប់ ហៅ
ក្ដុបទ្រេព ទាំងជប់ប្រការ ៗ ឲ្យបៀសអស់ទាំងនេះណា ឲ្យរៀន
លក្ខណា ទាំងប្រាំពីរផង ៗ គឺព្រះមានបុណ្យក្រទូង ទេសនាថែងបង
ជាបទគាថា ៗ មួយមាតុមួយមិត្តភរិយា ភាតុភរិយាជា ទាសភរិយា
ផង ៗ ទាំងបួនប្រសើរផុតហ្មង គួរឲ្យចាំបង ទុកក្នុងអង្គា ៗ រីឯហៅ
មាតុភរិយា ប្រពន្ធនោះជា លោកទុកស្មើម្ដាយ ៗ ចរិតបីប្រការក្នុង
កាយ មួយបង់ខ្វល់ខ្វាយ ប្រយោជន៍ឲ្យប្ដី ៗ បានចំរើនរុងរឿងល្បី
មិនឲ្យអាប់ប្ដី ឲ្យបានស័ក្តិយស ៗ មួយបើប្ដីស្លៀកពាក់ចាស់ យកថ្មីឲ្យ
ផ្លាស់ ចាស់ស្លៀកខ្លួនឯង ៗ បេះរៀបណ្ដាប់តាក់តែង ចំណីផងស្ងួន
រកមកឲ្យប្ដី ៗ មួយបើប្ដីឈឺចាត់អ្វី ព្រួយព្រើងមើលប្ដី រកថ្នាំសង្កូវ ៗ រក
ពេទ្យមេមត់ទូវគ្រូ គ្រោះយាមគន់គូរ មើលប្ដីឲ្យជា ៗ រីឯហៅភាតុភរិយា
ប្រសើរសោភា ប្រពន្ធស្មើបង ៗ នោះមានចរិតពីរផង ដូចប្អូននឹងបង
ចិត្តមូលមួយប្រាណ ៗ មួយធ្វើឲ្យប្ដីក្រៀមក្រាន្ត របស់ប្ដីបាន បេះទុក
ក្រោ ៗ មួយទោះព្វាក្យអ្នកណា គេតិះដៀលថា ស្រដីពីប្ដី ៗ ពុំ
គ្រអាស្រវអប្រិយ បេះការគេតិប្ដី ថែរបានជាសុខ ៗ ទោះបីបើប្ដី
មានទុក្ខ គិតឲ្យបានសុខ យកខ្លួនធានា ៗ មួយសោតឯមិត្តភរិយា
មានចរិតជា បីប្រការមិញ ៗ បីដូចគល់មិត្តសំឡាញ់ មានចិត្តអស់
អញ មិនឲ្យមានហ្មង ៗ បីដូចគល់ប្អូននឹងបង ប្រាស់យូរលង់ហោង

ទើបមកជួបគ្នា ៗ មានចិត្តប្រតិព័ទ្ធមហិមា ដ្បិតបានជួបគ្នា មិនឲ្យ
មានហ្មង ៗ មួយមានមារយាទកន្ទង់ ទោះឃើញប្រុសផង មិនល្អៀង
ចិត្តទៅ ៗ វិទាសកិរិយានោះត្រូវ ក្នុងមាត្រាត្រូវ ប្រពន្ធខ្ញុំប្តី ៗ ចរិត
៥ ប្រការខ្មី មួយចិត្តខាងប្តី ក្រែងប្តីវាយជេរ ៗ ប្រឹងចិត្តការគិតខ្មាស
គេ មិនឲ្យប្តីជេរ បន្ទោសខ្លួនបាន ៗ ទោះប្តីខឹងក្រៃប៉ុន្មាន មិនចេះហៅ
ហាន ឆ្លើយឈ្លោះតមាត់ ៗ មួយទោះប្តីនោះកាចក្តាត់ ខឹងដល់វាយ
វ៉ៃ ជេរហោរផេកទង់ ៗ មិនហ៊ានឆ្លើយឈ្លោះរំលង តតបទៅផង
ក្រែងព្ភកេរ្តិ៍ឆ្ងាយ ៗ មួយចេះប្រដាប់រៀបចាយ ប្តីដើរជិតឆ្ងាយ មិនហ៊ាន
បរិភោគ ៗ អត់ចាំទំព័ប្តីមក ជួបជុំទើបយក បរិភោគផងគ្នា ៗ នេះឯង
ហៅទាសកិរិយា សម្តេចគតំ ទេសនាប្រោសប្រាប់ ៗ បើអស់ស្រី
ណាបានស្តាប់ យកទុកជាច្បាប់ ក្នុងប្រាណសព្វថ្ងៃ ៗ លុះអស់អាយុ
ក្សិណក្ស័យ បានទៅកើតឮ តុសិតសួគ៌នាយ ៗ នឹងបានក្សេមក្សាន្ត
ពណ្ណពយ សេពសុខសប្បាយ និរទុក្ខភយា ៗ រីឯប្រពន្ធពុំជា ពេជ្ឈ-
ឃាតកិរិយា ចរិតមានបួន ៗ កុំឲ្យយកទុកក្នុងខ្លួន ឲ្យចៀសចេញជួន
កើតកម្មវេរ ៗ មួយចិត្តគំនិតចង់ជា ចាស់ឆ្លើយបំពារ បំពានឲ្យប្តី ៗ
ប្រទូស្តរឹងរូសខ្សូវខ្វី មិនចេះចាញ់ប្តី ថាឯងគ្រាន់បើ ៗ ឆ្លើយឆ្លង
សួរសង់បណ្តើរ ចង់ឈ្លោះឲ្យស្មើ ឲ្យលើសប្តីវិញ ៗ មួយមិនចង់
ធ្វើបំពេញ បង្អាប់ប្តីវិញ ឲ្យប្រើខ្លួនឯង ៗ អាងចេះជៀលតិះពុំក្រែង

ឲ្យប្តីស្តាប់ឯង ដោយចិត្តអន្ទពាល ។ មួយមានចិត្តនោះស្រើបស្រាល ចង់ត្រេកត្រអាល ចោរបេញក្បត់ប្តី ។ មួយបេចិត្តទ្រឹស្តិទ្រុសអប្រិយ ចង់សម្លាប់ប្តី ស្រឡាញ់ប្រុសទៀត ។ គិតការសម្លាប់បង្វៀត ទីងយកប្រុសទៀត ធ្វើប្តីមរណា ។ រីឯស្រ្តីភរិយា ចរិតពុំជា ប្រាំ-ពីរប្រការ ។ មួយមិនខ្លាចប្តីអាត្មា បង្គាប់ត្រង់ណា ពុំធ្វើតាមចិត្ត ។ មួយរឹងទទឹងរសៀមស្ងាត់ ប្តីសួរបីម៉ាត់ ពុំស្រដីផង ។ មួយប្តីស្រដីតទូង ប្រដៅច្បាប់ផង ពុំចូលចិត្តស្តាប់ ។ មួយមិនចង់ឲ្យប្តីគាប់ មិនចង់ប្រដាប់ ឲ្យប្តីកំប្លែង ។ មួយតោះទីងស្រដីឡើង ពាក្យធំប្រើង ចចេសទទឹងប្តី ។ មួយគោះប្តីណោះទុំស្រី រាំបំរើប្តី មិនឲ្យអាក់អន់ ។ ឃើញគាប់រង់ស្អប់ក្តាញ់ក្តាន់ ក្នុងចិត្តប្រចណ្ឌ ជេរថានាយអាយ ។ មួយផ្សិតប្តីមានសហាយ ហួរហែកស៊ុះសាយ ឲ្យប្តីអាស្រូវ ។ រីចោរភរិយានោះគួរ ចរិតពុំត្រូវ មានបីប្រការ ។ មួយចង់ចាយទ្រព្យប្តីណា ឲ្យខូចអសារ មិនគន់ជាល្អ ។ មួយប្តីឃ្លាតខ្ចីរក របស់បានមក មិនថែទាំទុក ។ លួចឲ្យទៅម្តាយឪពុក ប្តីសួររកមុខ មិនប្រាប់ឡើយណា ។ មួយខ្ជិលមិនចង់ធ្វើការ កុហកមុសា ថាឯងរវល់ ។ ដេកលេងចំរែងអស់កល់ លុះប្តីគេយល់ ពុតធ្វើជាឈឺ ។ ទទូរដេកថ្ងូរហ៊ឺ ។ ប្តីហៅមិនឮ ពុតចង់តែស្លាប់ ។ នេះហៅប្រពន្ធពុំគាប់ ស្រីណាកាន់ខ្ជាប់ ពុំដែលរសាយ ។ លុះអស់អាយុ

ក្ល័បក្លាយ ធ្លាក់ទៅអបាយ ទាំងបួនចំពូក ៗ តែងនឹងវេទុក្ខវេសោក
រដោះរួចមក កើតជាមនុស្សខ្ទើយ ៗ ហេតុអកុសលនេះហើយ ផ្សិតខ្លួន
ឥតត្រើយ ធ្វើខុសគន្លង ៗ ខុសវត្តប្រតិបត្តិចាំច្បង មិនរៀនមិនរង
ខុសទំនងច្បាប់ស្រី ៗ មាក់ស៊ាយនោះមានប្រាំបី មានក្នុងបាលី ព្រះធម៌
លោកថា ៗ មាក់ស៊ាយមួយនោះឯងណា ផ្សិតប្ដីពិការ មិនបានមួនមាំ ៗ
ខឹងស្អប់ធុញថប់មិនទ្រាំ មិនមានរកថ្នាំ គ្រូគ្រោះមេមត់ ៗ មើលប្ដីឲ្យ
ជាធាប់ធុត ខឹងវិញមិនអត់ បន់ឲ្យប្ដីស្លាប់ ៗ មាក់ស៊ាយមួយប្ដីខ្សត់ទ្រព្យ
គ្មានគេរក៏កោះគាប់ ស្មើនឹងអាត្មា ៗ ដៀលត្មះថាឆ្អះដោយសារ ព្រោះ
ខ្ជិលធ្វើការ ទើបគ្មានរបស់ ៗ មាក់ស៊ាយផ្សិតប្ដីអប្បយស ឯងត្រកូល
ខ្ពស់ ពូជពង្សពុំស្មើ ៗ ឆ្មើងខ្លួនឲ្យប្ដីបំរើ ឈ្មោះឡើងហើយដើរ ដៀល
ត្មះពូជពង្ស ៗ មាក់ស៊ាយមួយផ្សិតប្ដីល្ងង់ ខ្មៅខ្លួនទ្រមង់ ទ្រមក់យឹត
យូរ ៗ ដៀលត្មះពុំបេះអាសូរ សំដីខ្មោះខ្មួរ មិនក្រែងប៉ុនសក់ ៗ មាក់
ស៊ាយមួយប្ដីអាក្រក់ សាប់ខ្មៅប៉ប៉ក់ មុខអុតស៊ុសុស ៗ កន្ទួលពងលេ
ក្រទុះ សក់ស្កាញស្គូវស៊ុស ពោះធំប៉ុនពាង ៗ ខ្លួនឯងចំពែងរូបពង ខ្លួន
សល្អជាង ថាប្ដីមិនសម ៗ មាក់ស៊ាយមួយប្ដីមិនខំ ធ្វើការលោលាំ ខ្សែ
ឡូវដើរលេង ៗ ឆ្ងៀតឆ្លើយបោះពាក្យគគ្រេង ឈ្មោះដើរមិនឈ្នង
គិតខុសមាត្រា ៗ មាក់ស៊ាយមួយប្ដីផឹកស្រា ស្រវឹងបោលការ ដើរពេរង
តៃតោ ៗ ពាក្យគ្អេងកាំប្រៀងឡោៗ ឲ្យក្ដៅព្រុះពោ ផ្អើលភ្ញាក់កូនចៅ ៗ

ព្ធមាត់ប្តីហើយខឹងក្តៅ ប្រទេចផ្តេះទៅ តាមដោយចិត្តគ្នាញ់ ។ អាក់-
អាយមួយទៀតនោះមិញ ដៀតប្តីស្រឡាញ់ លលូកប្រឡែង ។ មួល
បិចពាក់ចុចជាល្បែង មិនមានកោតក្រែង បានចិត្តផ្ដេរវិញ ។ ដៀតតែ
យល់គេស្រឡាញ់ ស្រដីផងមិញ គំពេះគំរើយ ។ ធ្វើក្នាញ់បែរចេញ
ព្រងើយ នេរខឹងកន្តើយ ក្តិចក្នក់មាយ៉ា ។ ពុំបានគ្រៀមក្សាន្តទឹងគ្នា
មាក់អាយនេះជា គំរប់ច្រាំបី ។

កូនអើយនេះហើយច្បាប់ស្រី ឲ្យកូនពិសី រករៀនរក្សា ។ យក
ទុកក្នុងអង្គអាត្មា ប្រសើរក្តាត់ណា កើតសុខសួស្តី ។ ប្រសើរទាំង
នាលោកិយ ទោះបរលោកក្តី សឹងលុះប្រាថ្នា ។ ទោះចិត្តគន់គិត
សទ្ធា ជាពុទ្ធមាតា សឹងបានបរិបូណ៌ ។ ដូចចិត្តឆាប់ធុតពុំយូរ
គបកើតសម្បូរ សម្បត្តិទ្រព្យផង ។ កើតយសខ្ពង់ខ្ពស់កន្ទង់ យឺន
យូរផុតហ្ម៉ង ដូចក្តីប្រាថ្នា ។ ច្បាប់នេះឧត្តមថ្លៃថ្លា ទោះស្រីឯណា ព្រ
ហើយមានកីត្ត្យ ។ ជាល្អកម្របានស្តាប់ ស្តាប់ហើយចូរចាប់ ចូរចាំ
គ្រប់គ្នា ។ បានដល់មគ្គផលសួគ៌ា ប្រសើរសោភា ចូរចាំកុំភ្លេច ។
ចរចាអស់អាចិរាក្យពេចន៍ ពាក្យឥតកាព្យកិច្ច បរិបូណ៌ប្រពៃ ។ ប្រាជ្ញ
ប្រែឯនាងនៃ ខ្ញុំឈ្មោះម៉ឺនមៃ មែនមានសទ្ធា ។ មានចិត្តគួបគិត
កាព្យា កបកើតជ្រះថ្លា ត្រេកត្រង់កុសល ។ សទ្ធាប្រាថ្នាមគ្គផល

ផុលផុះយោបល់ លេចលើកទុកទៅ ។ ទោះបីសេចក្ដីខុសត្រូវ សូមទានជម្រូវ ជម្រង់ឲ្យផង ។ កុំគ្នះតិះដៀលឡើយហោង សូមសាងផលផង ទុកគសាសនា ។ សម្រាប់ជាច្បាប់មាត្រា សូរេចបកាពបរិបូណ៌ថៃឪចប់ ។

ចប់ច្បាប់ស្រី តែប៉ុណ្ណេះ ។

## ច្បាប់អរិយសត្ថា (១)

បទកាកគតិ

អរិយសត្ថា គន់គិតតែងការ ចង់ទុកជាច្បាប់ ឲ្យអស់សិស្សផង ត្រង់ត្រាប់សណ្ដាប់ យកជាតម្រាប់ តម្រង់អាត្មា ៗ ឲ្យមានប្រ-យោជន៍ ប្រយ័ត្នអសោច៍ ពល់រូបអ្នកណា អម្បាលមករៀន រៀនសាស្ត្រា ប្រយ័ត្នអាត្មា ការកេរ្តិ៍លោកិយ ៗ គោះនឹងចេញទៅ ប្រយោជន៍នានៅ ផ្គាប់ផ្គួនមន្ត្រី ឲ្យត្រូវនឹងច្បាប់ សណ្ដាប់សួស្ដី ដូចលោកស្រដី ប្រដៅទុកមក ៗ បើមិនចង់ទេ ចង់ទៅទំនេរ ជួញប្រែរកចិញ្ចឹមជីវិត គួរគិតរៀនយក របៀននោះមក ទើបរកទ្រព្យបាន ៗ រាយលេខទាត់ក្បាច់ សឹងផ្សំសម្រេច ឲ្យបានដឹងដាន ដឹងដើមដឹងចុង ដឹងបង់ដឹងបាន ដឹងគិតប្រមាណ កត់ត្រាបញ្ជី ៗ ឲ្យបានប្រយោជន៍ ប្រយ័ត្នអសោច៍ ជាអ្នកកេស៊ី សម្រាប់លោកិយ ប្រក្រតីជាទី សំគាល់បញ្ជី សៀនត្រាសៀវភៅ ៗ គន់គិតប្រយ័ត្ន អស់ទ្រព្យសម្បត្តិ ឲ្យស្អាត់ដោយនូវ រាយលេខទាត់ក្បាច់ ឲ្យស្រេចឃើញផ្លូវ សឹមថយចេញទៅ តាមផ្លូវលោកិយ ៗ ល្មមដឹងតិចច្រើន ល្មមដឹងកើន ទ្រព្យធនអ្វីៗ លេខនឹងអក្សរ កំដរស្មោះតើ សម្រាប់លោកិយ នោះឯងទើបត្រូវ ៗ បើតែរិលរល់ ខ្ជិលដេកស្រមេះ ស្រមូញស្មូញស្មូរ ស្រពាន់

---

១ ប្រហែលជាព្រះសង្ឃដែលមានសមណសក្តិជា ព្រះអរិយសត្ថា ទីមេគណឬចៅអធិការ ជាអ្នកតែងច្បាប់នេះ បានជាឲ្យឈ្មោះថា "ច្បាប់អរិយសត្ថា" ដូច្នេះ ។

លើឡើយ តន្ទើយលក់ទៅ នរណាទិញនៅ ដាស់តឿនឲ្យទៀត ៗ មិន ដឹងឬអ្វី កងពងលោកិយ ពជការបង្អៀត នរណាទុកឯង លេងវាយ ដៃព្រាត ឃើញហើយគេបៀត តម្រៀតពជការ ៗ ហេតុនោះគួរ គិត គួរកាន់គំនិត គួរគិតឧស្សាហ៍ សង្វាតរករៀន របៀនសាស្ត្រ តម្រិះប្រាជ្ញា បង្ការទុកទៅ ៗ ទើបដោះខ្លួនរួច ពប់ជាអ្នកស្រួប ដឹងគិត ពក់ជ្រៅ ក្នុងពងលោកិយ សេចក្តីឥឡូវ គិតឲ្យឃើញផ្លូវ ទឹងទៅមុខ ទៀត ៗ តែងឯងខ្លៅ គេថយចេញទៅ រកស៊ុបង្អៀត គិតគួរម្តេចម្តា ប្រពៃរបៀត ពឹងអ្នកកន្ទៀត ដូចខ្លួនកាលណា ៗ ហេតុតែខ្លួនឯង បេះគិតតាក់តែង ឲ្យគ្រប់ប្រការ ទាំងលេខទាំងក្បាច់ ស្រេចនូវអាត្មា ឯងឲ្យអស់ការ គិតគួរសព្វសាយ ៗ ទើបបានគេកោត គេមានចំណោទ គេកោតប្រាជ្ញប្រាយ គេយល់ឯងបេះ ចំណេះលៃបខាយ ពុំមានក្លែង ក្លាយ បំបាត់បានឡើយ ៗ តែងអ្នកខ្លៅ ផ្តេកផ្តិតចិត្តទៅ យកគេជា ត្រើយ កាលម្តងគេត្រង់ គង់ចិត្តនៅឡើយ ដល់ពីរដងហើយ គេប្រែ ប្រាជ្ញ ៗ គេគិតទាយទាត់ វាយលេខបំភ្លាត់ បំផ្លាញអាត្មា ចំណេញ ទៅគេ ទទេអសារ ខ្លួនឯងឥតការ ខាតទុនក្រខ្លួន ៗ នេះឯងក្មេងអើយ កុំប្រហែសឡើយ រៀនទុកជាក្បួន ទាំងលេខទាំងក្បាច់ ឲ្យស្រេច នៅខ្លួន អក្សរឲ្យសួន ទាន់ខ្លួននៅក្មេង ៗ តែចាស់បន្តិច វិញ្ញាណភ្លាំងភ្លេច គំនិតប្រែផ្សេង គិតការច្រើនមុខ កើតទុក្ខនេង ប្រាប់អស់ក្មេង ៗ

ឲ្យដឹងឲ្យហើយ ៗ កុំអាងថ្ងៃមុខ សម្បត្តិដែលនៅ មានច្រើននោះឡើយ ក្រែងផុតទិនថ្ងៃ ទឹងផុតទៅហើយ ខ្លួនខ្សោយដោតដើយ ផងនឹតល្ងង់ មោហា ៗ ក្រែងអស់តាំងទ្រព្យ នោះវាមិនខ្ជាប់ នៅនឹងអាត្មា ខ្លួនឯងដោតដៅ កំឡោះមោហា មិនបេះគ្រា មិនបានគុណទេ ៗ ខូចខាតមិនខាន គំនិតមិនបាន ប្រហែសខ្ញុំគេ គេវាយគេជាក់ គេប្រើគេជេរ មិនឲ្យទំនេរ ខ្មាសគេតិះអ្វី ៗ ដូច្នេះគួរគិត គួរឃើញគំនិត គួរគិតសេចក្តី ជាមនុស្សដូចគេ គួរតែឃ្លាតខ្ចី រំពឹកស្មារតី ស្រឡាញ់រៀន កុំគិតខ្ជិលពេក កុំគិតពួនដេក កុំគិតវេះវៀន កុំគិតមានពុត រមិតកិបកៀន កុំគិតអៀនប្រៀន វេះវៀនចិត្តកាច ៗ ឲ្យរៀនចិត្តល្អ ដឹងធម៌អក្សរ គួរគិតកោតខ្លាច ការកើតប្រយ័ត្ន គួរកាត់ចោលកាច គួរឲ្យខ្លួនខ្លាច កុំឲ្យត្រូវទោស ៗ ពាក្យគ្រូដូនណាស់ ជំទៀលដល់ចាស់ ពីព្រេងមុននាយ ឯត្រង់ពាក្យម្តាយ ទំនាយគ្រូទាយ នេះឯងមិនឆាយ អាក្រក់ណាស់ណា ៗ ឲ្យប្រុងប្រយ័ត្ន បម្រើប្រណិប័តន៍ កាត់ចិត្តស្នេហា កុំឲ្យអន់អាក់ ថ្នាំងថ្នាក់ចិន្តា ត្រូវទាយហើយណា ធុតធាប់ណាស់ហោង ៗ ឲ្យដឹងបាបបុណ្យ ស្គាល់ទោសនឹងគុណ ជាទុនទៅមុខ គុណគ្រូបាធ្យាយ គុណម្តាយអាពុក រៀមច្បងទំនុក ឲ្យសុខអនុកូល ៗ គ្រូមួយផងគ្នា រួមរ័ក្ខចិត្តជា ស្នេហាមិត្រមូល កុំនាំអុជហេតុ បំបែកចេញចូល កាប់កិនត្រកូល បង្កើតមាត់ក ៗ

កុំធ្វើមាក់ងាយ ទឹងគ្រប់ផ្ទាយ រៀនចិត្តឲ្យល្អ ទោះអ្នកឯណា វែកផ្លូវ
អក្សរ អ្នកនោះឯងអរ ឲ្យចិត្តមេត្រី ៗ កុំឲ្យសៅហ្មង លើលោកកន្ទង
ពោលពាក្យស្រដី រឹងរូសទ្រគោះ ឈ្លាសឈ្លោះសេចក្ដី កើតទោស
អប្រិយ ដេរពោលប្រមាថ ៗ អ្នកនោះស្មើគ្រូ បង្កើតអកិរ្ត គុណ
ទេទុកទេ គេជួយប្រដៅ គេហៅទុហាត ដាស់តឿនសង្វាត ឲ្យឯង
ចេះចាប់ ៗ បើឯងចេះហើយ កុំភ្លេចគុណឡើយ ឲ្យដឹងដោយច្បាប់
គួរគិតកោតខ្លាច ដើរតាមសណ្ដាប់ គន្លងធម៌ច្បាប់ កុំឲ្យមាក់ងាយ ៗ
នេះឯងគន្លង ត្រឹមត្រូវទំនង អំពីព្រេងនាយ ឯកផងឡូវ ច្រើនតែ
មាក់ងាយ ចេះហើយដេរម្ដាយ ប្រមាថគ្រូវិញ ៗ ហេតុដូច្នោះឯង
លោកិយយល់ស្ដែង តែងឃើញម្ដេចមិញ ហិនហោចសូន្យសុង លិច
លង់ទៅវិញ ទោសនោះឯងមិញ កើតពីឯណា ៗ កើតពីចិត្តឯង
បង្កើតស្វះស្វែង បំផ្លាញអាត្មា ពេលពលក្នុងពោះ ចេះក្នុងទុក បង្កើត
ទោសា ឲ្យទុក្ខរូបឯង ៗ ចេះតែបន្តិច លើកខ្លួនកំប៉ុច កំប៉ោងឥត
ក្រែង តែងឃើញរៀងមក យ៉ាងដូច្នេះឯង ម៉្លោះហើយកកែង ខុសទឹង
ទេត្តា ៗ រីអ្នកចិត្តល្អ ដឹងធម៌អក្សរ ចេះពិចារណា ស្គាល់គុណទឹង
ទោស សន្ដោសអាត្មា អត់ទុនចិន្តា ពុំដែលសៅហ្មង ៗ អ្នកនោះ
ឯងនៃ សោភសឹងប្រពៃ សួស្ដីគន្លង បរលោកលោកិយ ឥតបីសៅហ្មង

តាំងទេព្ដាផង ចំរើនឲ្យសុខ ៗ ដរាបរៀងទៅ សុខពិតឡូវ រៀងទៅមុខ ចៀសចាកប្រាសប្រាណ ពីស្ថាននរក រៀងរូបបានសុខ ដល់សួគ៌ាល័យ ៗ

អរិយសត្តា គន់គិតតែងតារ តែងចងសេចក្ដី តម្រង់តម្រាប់ ជាច្បាប់យ៉ាងថ្មី ដាស់តឿនស្រដី សំស្រសេចប្រការ ៗ គួរគិតរករៀន កិច្ចការរបៀន របបសាស្ត្រា តាមច្បាប់ទំនាន ឲ្យនានអាត្មា រៀងរាល់រូបា សួរបេបប់ហោង ៗ

ចប់ច្បាប់អរិយសត្តាតែប៉ុណ្ណេះ ៗ

# គម្ពីរបញ្ចតន្ត្រ

## គម្ពីរប្រជុំនិទាន៥ពួក

នេះជាឈ្មោះគម្ពីរមួយដែលប្រជុំនិទានផ្សេងៗ ដែលល្បីល្បាញណាស់នៅក្នុងប្រទេសឥណ្ឌាសម័យបុរាណ ដ្បិតមាននិទានជាច្រើនណាស់ ដែលគេបានប្រែចេញពីភាសាសំស្ក្រឹត មកជាភាសាអ្នកស្រុកអាស៊ី និងភាសាពួកឩរ៉ុប កាលពីពុទ្ធសករាជ ១១១៣ ឡើងទៅ ។ ឯនិទានរឿងព្រេងអស់នេះ គេសន្មតថា កំណើតដើមរឿងនៅប្រទេសឥណ្ឌាទាំងអស់ ជាគម្ពីរមួយយ៉ាងចាស់ ប្រហែលកើតឡើងក្នុងរវាងពុទ្ធសករាជ ៦៥០ ។

អ្នកតែងរឿងជាជាតិព្រាហ្មណ៍ម្នាក់ ឈ្មោះវិស្ណុស្វរ័ន ។ ឯគម្ពីរនេះមានប្រយោជន៍ក្នុងការសិក្សារបស់ពួកក្សត្រ សម្រាប់ឲ្យពួកក្សត្រចេះរបៀបត្រួតត្រាស្រុកទេស និងប្រព្រឹត្តឲ្យត្រូវគន្លងផ្ទាល់អង្គក្សត្រផង ។ មានរឿងខ្លះ គេឃើញមានក្នុងរឿងជាតក ដែលដកយកមកអំពីគម្ពីរបញ្ចតន្ត្រ មានសុភាសិតជាច្រើន ដែលប្រកបដោយសីល ធម៌, សម្មាអាជីវៈ និងប្រសាសនោបាយរបស់ក្សត្រ ៗ រឿងនេះសុទ្ធតែតែងជាភាសាសំស្ក្រឹត ឯរឿងខ្លះ នាំឲ្យមានប្រយោជន៍ដល់ចិត្តគំនិតនោះ ដូចនិទានដែលយើងរើសប្រមូលមកនេះ ។

# អំពីមេបង្កងមួយជួយជីវិតព្រាហ្មណ៍ម្នាក់

ក្នុងតំបន់មួយនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះព្រហ្មទត្ត[១] ។ ព្រាហ្មណ៍នេះ ត្រូវការធ្វើដំណើរចេញទៅកាន់ស្រុកមួយទៀត ដោយកិច្ចធុរៈដែលខានពុំបាន ។ មាតាគាត់ទើបសួរទៅគាត់ថា "ម្នាលកូន, ហេតុដូចម្តេចក៏កូនចេញទៅតែម្នាក់ឯង? ចូរឯងរកសម្លាញ់ម្នាក់ជាគ្នា ដើរផ្លូវទៅជាមួយផង ។ ព្រាហ្មណ៍ជាកូនពោលតបទៅវិញថា "លោកម្តាយ, ខ្ញុំបាទមិនខ្លាចអ្វីទេ ផ្លូវនោះឥតមានគ្រោះថ្នាក់អ្វីទេ ខ្ញុំបាទមានការសំខាន់មួយខានទៅពុំបាន ទុកជាម្នាក់ឯង ខ្ញុំបាទក៏គោងតែទៅឥឡូវនេះដែរ ។ ឯម្តាយកាលបានឃើញសេចក្តីតាំងចិត្តដាច់ស្រេចដូច្នោះ ទើបនាងទៅដងយកមេបង្កងមួយ អំពីអណ្តូងជិតខាងលំនៅ ហើយនិយាយទៅនឹងកូនថា "កូន, ប្រសិនបើត្រូវតែទៅខានពុំបានទេ ចូរឯងយកមេបង្កងនេះធ្វើដំណើរទៅជាមួយផងចុះ ។ ឯព្រាហ្មណ៍បានទទួលយកដោយសេចក្តីគោរព យកដៃទាំងពីរទ្រហើយដាក់បង្កងក្នុងកន្ទោងកប្បូរ ហើយដាក់ទៅក្នុងថង់ប្រាក់ ១ ជាន់ទៀត ហើយចេញដើរទៅដោយប្រញាប់ ។ ប៉ុន្តែកាលដែលព្រាហ្មណ៍កំពុងដើរទៅនោះ ត្រូវកំដៅថ្ងៃជាខ្លាំងក៏ចូលទៅជ្រកក្រោមដើមឈើ ១ ដើម ដែលនៅក្បែរផ្លូវហើយដេកលក់ទៅ

---

១ ឈ្មោះនេះប្រែថា ដែលព្រហ្មប្រទានមក ។

ដោយសេចក្ដីក្រៀមក្យាន្ត ៗ ខណៈនុ៎ះ មានពស់ខ្មៅ ១ ចេញមកពីប្រ-ហោងដើមឈើ ហើយវារទៅលើខ្លួនព្រាហ្មណ៍នោះ តែពស់ធុំក្លិនកប្បិរ ទើបវារចេញពីខ្លួនព្រាហ្មណ៍ ហើយហែកថង់ប្រាក់នោះចេញ ទើបខាំស៊ីកន្ទោងកប្បូរដែលនៅខាងក្នុងថង់ ដោយចិត្តលោភលន់ឃ្លានជាខ្លាំង ៗ ឯមេបង្កងក៏ត្រូវពស់នោះស៊ីដែរ តែពស់លេបចូលទៅក្នុងបំពង់កស្លាក់ ហើយពស់នោះស្លាប់ទៅ ៗ លុះដល់ព្រាហ្មណ៍ក្រោកពីដេកឡើងក្រឡេកមើលទៅខាងៗខ្លួន ក៏ឃើញពស់ខ្មៅមួយស្លាប់នៅក្បែរខ្លួន ហើយនៅក្បែរពស់នោះឃើញមេបង្កង ៗ កាលព្រាហ្មណ៍បានឃើញហេតុដូច្នោះហើយក៏គិតថា: ឱ! មែនហើយ ម្ដាយអញបាននិយាយនឹងអញថា (ទៅទីណា) ត្រូវតែមានគូកនទៅជាមួយផង មិនត្រូវចេញដំណើរទៅតែម្នាក់ឯងឡើយ ៗ ដោយហេតុអញប្រតិបត្តិតាមដម្បូន្មាន របស់ម្ដាយដោយសេចក្ដីជឿយ៉ាងពិតប្រាកដ ទើបអញបានរស់រួចពីសេចក្ដីស្លាប់ពីពស់ចឹក ដោយមេបង្កងជួយសង្គ្រោះអញ ៗ មួយវិញទៀត គេបានពោលដូច្នេះថា:

សូម្បីតែគូកនដើរផ្លូវដ៏មានកំឡាំងទន់ខ្សោយយ៉ាងណាក៏ដោយ ក៏ជាហេតុនាំឲ្យកើតសុខដែរ មើលចុះ អ្នកដំណើរម្នាក់បានផុតពីត្រូវពស់ចឹកស្លាប់ ដោយសារគូកនដែលដើរផ្លូវទៅជាមួយនឹងខ្លួន ៗ

## អំពីអណ្ដើកនិងហង្សពីរ

(រឿងនេះមានសេចក្ដីស្របគ្នាក្នុងជាតក និងអវទាន)

នៅក្នុងស្រះ ១ នោះ មានអណ្ដើក ១ ឈ្មោះកម្ពុគ្រីវៈ[1] ហើយអណ្ដើកនេះ មានសំឡាញ់ពីរជាសត្វហង្ស ឈ្មោះសង្កត[2] ១ ឈ្មោះវិកត[3] ១ សត្វទាំងពីរនេះ ក៏មានចិត្តស្រឡាញ់អណ្ដើកដោយស្មោះត្រង់ ហើយតែងនាំគ្នាទៅកាន់មាត់ស្រះនោះជានិច្ច ហើយបានដំណាលរឿងក៏ឲ្យអណ្ដើកស្ដាប់សព្វគ្រប់ អំពីរឿងទេវឫសី[4] ព្រហ្មឫសី[5] និងរាជឫសី[6] ដរាបដល់ព្រះអាទិត្យអស្ដង្គតទៅ ទើបនាំគ្នាទៅសំបុករបស់ខ្លួនវិញ ។ លុះក្នុងសម័យតៗមក ទីនោះក៏រាំងឥតទឹកភ្លៀង ស្រះនោះក៏កាន់តែស្ងួតបន្តិចម្ដងៗ ។ សត្វទាំង ៣ ក៏កើតទុក្ខដោយគ្រោះថ្នាក់នេះ ទើបហង្សទាំងពីរនិយាយគ្នាថា "ឱ! សំឡាញ់ស្មោះចិត្តអើយ ឥឡូវនេះស្រះនេះមានតែភក់, ចុះសំឡាញ់គិតគូរដូចម្ដេច? យើងព្រួយចិត្តណាស់ សព្វថ្ងៃនេះ" ។ កាលកម្ពុគ្រីវៈ បានឮដូច្នោះហើយ ទើបនិយាយឡើងថា "អើ! សំឡាញ់ ប្រសិនបើគ្មានទឹក, ចំណែកខ្លួនខ្ញុំមិនមានផ្លូវរស់តទៅទៀតទេ ដូច្នេះត្រូវយើងគិតគូររកឧបាយដោះខ្លួន ដ្បិតគេតែងពោលទុកថា :

---

១ ប្រែថាមានកពក្អាក់ ។ ២ ប្រែថា តូច ។ ៣ ប្រែថា ធំ ។ ៤ ប្រែថា ឥសីទេវតា ។ ៥ ប្រែថា ឥសីតាមរបៀបព្រាហ្មណ៍ ។ ៦ ប្រែថា ឥសីក្នុងពួកក្សត្រ ។

"ញាតិសាច់ក្តី មិត្រក្តី ក្នុងពេលដែលមានគ្រោះថ្នាក់មកដល់ អ្នកសប្បុរស តែងចំរើនខ្វល់ខ្វាយជួយដោយមុឹងម៉ាត់" ពាក្យនេះហើយ ដែលលោកមនុស្សបានពោលទុកមក ដូច្នេះចូរសំឡាញ់យកវត្ថុមួយជា ខ្សែយ៉ាងវែង ឬកំណាត់ឈើ ១ តូចជាដើម ហើយត្រូវនាំយើងទៅរកស្រះណាមួយដែលមានទឹកច្រើន ៗ

ឯយើងនឹងខាំត្រង់កណ្តាលឈើនោះនឹងធ្មេញយើង សំឡាញ់ទាំងពីរពាំចុងកំណាត់ឈើម្ខាងម្នាក់ ហើយនាំយើងទៅកាន់ស្រះនោះ ។ ទើបហង្សឆ្លើយឡើងថា "ឱ! សំឡាញ់ស្មោចក្តអើយ! យើងនឹងធ្វើដូច្នោះក៏បាន ប៉ុន្តែសំឡាញ់ឯងសន្យាថា កុំនិយាយអ្វីឲ្យសោះទើបបាន តែបើមាត់និយាយហើយ មុខជាសំឡាញ់របូតជ្រុះពីបង្គងឈើមិនខាន ហើយសំឡាញ់នឹងខូចខ្លួនជាមិនខាន អណ្តើកនិយាយឡើងថា ពិតដូចសំឡាញ់ទាំងពីរពោលមែន បើដូច្នេះ ខ្ញុំសុំធ្វើសន្យាថានឹងនៅស្ងៀមតាំងពីឥឡូវនេះទៅ ដរាបដល់ធ្វើដំណើរទៅតាមអាកាស ទាល់តែខ្ញុំបានដល់ទៅស្រះនោះ ៗ

កាលព្រមព្រៀងគ្នាធ្វើដូច្នេះហើយ ទើបកម្តុគ្រីវៈ ក្នុងពេលដែលធ្វើដំណើរទៅតាមអាកាសនោះ បានសង្កេតឃើញភូមិមួយនៅពីខាងក្រោម ៗ ពួកអ្នកស្រុកនៅភូមិនោះ បានឃើញដំណើរសត្វទាំង ៣ ដូច្នោះ ក៏និយាយឆោឡោឡើងដោយសេចក្តីអស្ចារ្យៈ ហៈហា! អ៊ុះហ៊ន៎!

មូលដូចកង់មានសត្វបក្សីពាំនាំហើរទៅ! ឯកមន្ត្រីៈ កាលបើបានឮសំដីវែករពោករបស់អ្នកស្រុកដូច្នោះ ទ្រាំអត់មិនបាន ក៏និយាយចេញទៅថា "អើ! ចុះស្បូវវែករពោកអ្វីហ្នឹង? អណ្តើកនេះគ្រាន់តែហាមាត់និយាយមិនទាន់បានពាក់កណ្តាលមាត់ ក៏របូតខ្លួនចុះពាកបង្គង់ទ្រុះមកបែកខ្ទេចជាបំណែកៗ ក្នុងចំណោមអ្នកស្រុកទាំងឯង ។

ហេតុដូច្នេះហើយ ទើបមានពាក្យពោលទុកមកថាៈ "នៅនាលោកិយនេះ អ្នកឯណាមួយ ដែលមិនព្រមធ្វើតាមដម្បូន្មាន ដែលមានមេត្រីចិត្តស្មោះត្រង់ទេ នឹងវិនាសខ្លួនមិនខាន ដូចជាអណ្តើកទៅ ដែលធ្លាក់ចុះពីបង្គង់ឈើដូច្នោះដែរ" ។

(នៅមាននិទានដទៃ ៗ តទៅទៀត)

ពង្សាវតារក្រុងរោម

វគ្គទី ៥

# រោមតាំងមហាអាណាចក្រ

កាលដែលសេសារស្លាប់ទៅនេះ ធ្វើឲ្យក្រុងរោមកើតចលាចលវរវឹក ឡើងយ៉ាងធំសំបើម ពួកដែលធ្វើការសម្លាប់សេសារគ្រានេះ មានសេចក្តីគាំងចិត្តថា នឹងធ្វើក្រុងរោមឲ្យប្រតិបត្តិតាមរបៀបចាស់ គឺមិនឲ្យធ្លាក់នៅក្នុងកណ្តាប់ដៃរបស់បុគ្គលម្នាក់ៗ ទើបពួកនេះនាំគ្នាសម្លាប់សេសារ លុះសម្លាប់ហើយក៏ចេញពីទីប្រជុំសេណាត់ស្រែកប្រាប់ប្រជាជនទូទៅថា "ឥឡូវនេះប្រជាជនគ្រប់គ្នាមានឥស្សរភាពពេញទី មិនបាច់នៅក្រោមអំណាចរបស់បុគ្គលណាមួយទៀតឡើយ" តែពួកប្រជាជនមិនបាននាំគ្នាត្រេកអរ បែរជាទោមនស្សនឹកស្តាយសេសារទៅវិញ ដោយនឹករលឹកដល់ម្ហូបបុណ្យដ៏ក្សេមក្សាន្ត ដែលសេសារធ្លាប់ធ្វើមកនាំឲ្យពួកគេបានសេចក្តីសុខសប្បាយជាច្រើន ទើបពួកនេះកើតទោមនស្សសៅសោកប្រាកដឃើញជាក់ស្តែង ។ ឯសភាសេណាត់ក៏នឹកឃើញស្តាយក្រោយថា ការដែលសេសារត្រូវបង់ជីវិតទៅគ្រានេះ មិនមែនជាប្រយោជន៍ដល់សភានោះឡើយ ព្រោះក្នុងសម័យនោះ នៅក្រុងរោម បើអ្នកឯណាមានកំឡាំងទាហាននៅក្នុងដៃ រមែងចង់បានអំណាចនៅក្នុងរោម

ហើយអ្នកណាមួយនឹងដណ្ដើមអំណាចនេះទៅកាន់ ក៏គ្មានអ្នកឯណាដឹងបានឡើយ ។ ការដែលសកាមានសេចក្ដីព្រួយបារម្ភនេះជាការត្រឹមត្រូវណាស់ ព្រោះតមកមិនយូរប៉ុន្មានអង់តួន (Antoine) ធ្លាប់ធ្វើជានាយទាហានដ៏ក្លាហានមួយរបស់សេសារ មានមនុស្សគាប់ចិត្តច្រើន ទើបចាប់យកឱកាសនេះធ្វើខ្លួនឲ្យមានអំណាចឡើង ។ បុរសនេះឯងដឹងច្បាស់ថាប្រជាជនមានចិត្តស្រឡាញ់នឹងស្ដាយសេសារណាស់ ទើបនាំយកពន្ទីស្មើរបស់សេសារជាគ្រឿងផ្សាយអំណាចរបស់ខ្លួន ។ នៅថ្ងៃធ្វើបុណ្យសពសេសារអង់តួនជាអ្នកតាត់តែង បានស្ងូត្រសុន្ទរកថាក្នុងទីប្រជុំជនលើកសរសើរសេសារជាពន្ទឹក ទើបនាំឲ្យប្រជាជនកាន់តែនឹកសង្វេគស្ដុតចិត្តអាណិតនឹកស្ដាយសេសារកាន់តែខ្លាំងឡើង អង់តួនបានយកអាវផាយរបស់សេសារ ដែលប្រឡាក់ទៅដោយឈាមនឹងមានស្នាមត្រូវគេចាក់ដោយអាវុធ ២៨ អន្លើ លើកបង្ហាញឲ្យប្រជាជនមើល គ្រាន់តែប្រជាជនបានឃើញ ក៏មានចិត្តទោសោះកើតឡើងពល់គ្នា រកសងសឹកអ្នកដែលធ្វើការឃាតកម្មសេសារមួយរំពេច ទាល់តែព្រូទុសព្រមទាំងបក្សពួករត់ចេញពីក្រុងរោមទៅ ។

ក្នុងវេលាដែលកំពុងចលាចលនេះ អុកតាវ (Octave) ដែលជាក្មួយនឹងជាកូនធម៌របស់សេសារ កំពុងសិក្សាវិជ្ជានៅក្រុងអាថែន្សនោះ លុះបានដំណឹងថា សេសារស្លាប់ក៏ប្រញាប់ចូលមកក្រុងរោមវិញ ដើម្បីទទួល

មរដករបស់អាពុកធំ ៗ ក្នុងខណៈអុកតាវមានអាយុត្រឹម ១៩ ឆ្នាំ មានរូបរាងតូច ពិការជើងហើយច្រើនមានរោគ និយាយសំដីមិនគ្រោះក្បាយ ទាំងខ្លាចច្រើន ខ្លាចងងឹតនឹងសូរផ្គរ តែជាមនុស្សប៉ិនប្រចុប ៗ លុះមកដល់ក៏និយាយលើកជើងដំកើងសភាសេណាត៍ ហៅស៊ីសេរ៉ុងថាឪពុក បំណាយប្រាក់ចែកចាយពួកទាហានចាស់របស់សេសារ មិនយូរប៉ុន្មានក៏បានធ្វើជាអធិបតីនៃកងទ័ព ៗ ឯស៊ីសេរ៉ុងមានចិត្តទៀយណាយនឹងអំណាចរបស់អង់ត្វាននោះ ក៏ទុកសង្ឃឹមថា នឹងបានអុកតាវជួយជាកំ-ឡាំង ដើម្បីផ្តាច់អំណាចរបស់អង់ត្វាន ៗ នៅវេលានោះ អង់ត្វានបានចេញពីក្រុងរ៉ូមទៅតាមចាប់ប្រ៊ុទុស ទើបស៊ីសេរ៉ុងប្រកាសកាត់ឈ្មោះអង់ត្វានចេញពីអំណាចច្បាប់រ៉ូម ហើយតាំងអុកតាវជាមេទ័ពសម្រាប់ចាត់ការប្រាបប្រាមអង់ត្វាន បើអង់ត្វានមកបង្កការចលាចលដល់ក្រុងរ៉ូម ៗ

ទើបអុកតាវប្តឹងសុំឲ្យតាំងខ្លួនជាកុងស៊ុលផង ខាងសភាសេណាត៍មិនយល់ព្រម ចួនជាអង់ត្វានដែលចេញទៅប្រាបប្រាមនោះ បានធ្វើស្ពានមេត្រីនឹងរដ្ឋបាលប្រទេសកូលនឹងប្រទេសគាលី ហើយមានកងទ័ពមកជាមួយផង ៗ ឯអ្នកទាំងពីរគឺអង់ត្វាននឹងអុកតាវសឹងយល់ដឹងការច្បាស់ថា ការគិតធ្វើការឲ្យបានផលប្រយោជន៍ដល់ខ្លួនឯងនោះ ត្រូវតែរួមកំ-ឡាំងគ្នាតទល់នឹងសភាសេណាត៍ ដែលជាពួកញុះញង់ឲ្យធ្វើការសម្លាប់

សេសារ មានបុរសម្នាក់ទៀត ជាមន្ត្រីធំត្រួតត្រាប្រទេសកូលមកចូលរួមជាមួយផង ឈ្មោះលេពីត (Lépide) បុរសទាំង ៣ នាក់នេះរួបរួមគ្នាជាគណៈមួយឡើង ហៅតាមប្រវត្តិសាស្ត្រថា ទ្រីយុមវិរ៉ាតទី ២ (Deuxième Triumvirat) ហើយបែងខេត្តដែនបែកគ្នាត្រួតត្រា ១ ភាគម្នាក់ ៗ កិច្ចការដែលផងទាំង ៣ នាក់ចាប់ធ្វើជាដំបូង គឺតាមចាប់ប្រហារជីវិតពួកដែលសម្លាប់និងពួកដែលញុះញង់ឲ្យសម្លាប់សេសារអស់ចំនួនច្រើន ឯស៊ីសេរុងដែលអុកតាវធ្លាប់ហៅថាឪពុក ៗ នោះ ក៏ត្រូវចាប់យកទៅប្រហារជីវិតដែរ ។

លុះរៀបចំធ្វើដូច្នេះហើយ ទើបអុកតាវនិងអង់ត្វានក៏នាំគ្នាឆ្លងសមុទ្រអាឌ្រិយ៉ាទិកទៅតាមចាប់ប្រ៊ូទុស ដែលចេញទៅតាំងកងទាហានចាំទប់ទល់នៅក្នុងខេត្តម៉ាសេដ្វាន បានវាយកងទ័ពប្រ៊ូទុសបាក់បែកខ្ចាត់ខ្ចាយ ហើយប្រ៊ូទុសក៏សម្លាប់ខ្លួនឯង ក្នុងពុទ្ធសករាជ ៥០១ (មុន គ.ស.៤២) ។

តអំពីនោះ អង់ត្វានក៏ចេញទៅប្រទេសអេស៊ីប្ត ដើម្បីប្រាប់ប្រាមប្រទេសអេស៊ីប្ត ដែលជាអ្នកជួយឲ្យកំឡាំងដល់ប្រ៊ូទុសកាលដែលបានជួបនឹងព្រះនាងក្លេអូប៉ាត្រ (Cléopâte) ក៏ភ្លេចភ្លាំងកិច្ចការមុខក្រសួងរបស់ខ្លួនអស់រលីង ទើបអុកតាវចេញធ្វើការតែម្នាក់ឯង ពោលគឺគោងទៅប្រាបប្រាមកូនប៉ុមប៉េដែលតាំងកងទ័ពជើងទឹកយ៉ាងរឹងប៉ឹង ហើយជាម្ចាស់សមុទ្រមេឌីតេរ៉ាណេ ៗ ជ័យជំនះរបស់អុកតាវនេះ សម្រេចបាន

ដោយអាស្រ័យសម្លាញ់ខ្លួនម្នាក់ឈ្មោះអាគ្រិបប៉ា (Agrippa) ៗ ឯលេពីត ដែលជាសម្លាញ់រួមគណៈជាមួយគ្នាក៏ប្រាកដថា បានធ្វើការជាច្រើនដែរ តែមិនបានចេញមុខចេញមាត់មាំមួនទេ តែអុកតាវ៍ក៏មានសេចក្ដីអរគុណ ទាំងដឹងគុណហើយតាំងឲ្យជាអ្នកសម្រេចកិច្ចការខាងសាសនា ៗ

តាំងអំពីនោះមក អ្នកដែលប្រណាំងប្រជែងដណ្ដើមអំណាចគ្នាយ៉ាងមុឹងម៉ាត់ មានត្រឹម ២ នាក់ គឺអុកតាវ៍ទឹងអង់ត្វានតែពីរនាក់ប៉ុណ្ណោះ ៗ ឯអង់ត្វាននោះ កាលចេញពីប្រទេសអេស៊ិប្ដ៍ទៅបានទៅច្បាំងទឹងពួកប៉ារ-ថីតែបរាជ័យ គួរតែអង់ត្វានវិលចូលទៅក្រុងរោមវិញ បែរជាទៅរកព្រះនាងក្លេអូប៉ាត្រទៀត ហើយគ្រានេះ អង់ត្វានក៏វង្វេងកាន់តាំងនៅក្នុងអេស៊ិប្ដ៍ហើយគិតតាំងអាណាចក្ររបស់ខ្លួនមួយឡើងនៅចំណែកទិសខាងកើតដោយឡែកទៅ ៗ ឯអុកតាវ៍ក៏ព្យាយាមពន្យល់ឲ្យប្រជាជនយល់ថា អង់ត្វានជាមនុស្សក្បត់នឹងជាតិខ្លួន ទើបត្រូវធ្វើសង្គ្រាមប្រាបប្រាមអង់ត្វានទឹងព្រះនាងក្លេអូប៉ាត្រ ៗ អង់ត្វានលើកកងទ័ពជើងទឹកទឹងជើងគោកមកតាំងចាំទទួលនៅប្រទេសក្រិក ៗ លុះកងទ័ពអេស៊ិប្ដបរាជ័យហើយ ព្រះនាងក្លេអូប៉ាត្រនាំអង់ត្វានរត់ចូលមកប្រទេសអេស៊ិប្ដ៍វិញ ៗ អុកតាវ៍ដេញតាមច្បាំងអង់ត្វានរហូតដល់ស្រុកអាលេក្សង់ឌ្រិ (Alexendrie) អង់ត្វានក៏ចាញ់គេទៀត ហើយត្រូវព្រះនាងក្លេអូប៉ាត្របញ្ឆោតឲ្យផឹកថ្នាំបំពុលស្លាប់ទៅ ដូចមានសំដែងក្នុងពង្សាវតារប្រទេសអេស៊ិប្ដ៍នោះស្រាប់ ហេតុនេះហើយ

ដែលនាំឲ្យអុកតាវបានធ្វើជានាយរៅហ្វាយក្រុងពេមតែម្នាក់ឯង ហើយតាំងអំពីនោះមករេពុយព្លិកក្រុងពេមក៏ផុតរលត់ត្រឹមប៉ុណ្ណឹង គឺរបៀបត្រួតត្រាក្រុងពេម បានផ្លាស់ប្ដូរជារបៀបកជាធិបតេយ្យ ក្នុងពុទ្ធស-ករាជ ៤១២ ។

## សម័យក្សត្រអាជ្ញាសិទ្ធិរាជ្យ

តាមដោយពិត ការផ្លាស់វិធីត្រួតត្រាស្រុក ពីរបៀបរេពុយព្លិកមក ជារបៀបកជាធិបតេយ្យនេះ គឺអុកតាវ (កាលបានប្រកាសខ្លួនជាក្សត្រឡើងហើយ ក៏តាំងឈ្មោះខ្លួនថា អុគុស្តុសេសារ[១]) បានធ្វើជាធំមានអំណាចយ៉ាងសំបើមនៅក្រុងពេម ប៉ុន្តែរបៀបត្រួតត្រាក្រុងពេមមិនបានប្រែប្រួលយ៉ាងណាឡើយ ទាំងសភាព្រឹទ្ធសភាសេណាត៍គង់មាននៅជានិច្ច ថែមទាំងតាត់តាំងកុងស៊ុលឡើងវិញទៀតផង ។ ព្រះបាទអុគុស្តុសេសារទ្រង់បានឃើញគួយ៉ាងមកហើយថា ការតាំងខ្លួនជាឌិក-តាទ័រនៃក្រុងពេមនេះឲ្យទោសច្រើនជាពន់ក ហេតុនេះទើបទ្រង់ប្រគល់អំណាចឲ្យសភាផ្សេងៗ កាន់កាប់រក្សាតាមដើម តែមិនបានទ្រង់បណ្ដោយ

---

១ ពាក្យថា សេសារនេះ ពីដើមមកជាឈ្មោះរបស់មហាបុរសម្នាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញដូចបានពោលរួចមកហើយ តមកគ្រាក្រោយទើបសំដៅសេចក្ដីថា ព្រះចៅផែនដី តែក្រុងពេមគ្រានោះគួរហៅស្ដេចត្រង់រាជ្យថា “ព្រះចៅផែនដី ឬព្រះរាជា” បែរជាហៅថា សេសារ តមករុស្ស៊ីនាំទៅប្រើហៅថា “សារ៍” អាល្លឺម៉ង់យកទៅប្រើថាកៃសារ (ឬកៃសែរ) ។

ឲ្យពួកអស់នោះ ទុកទ្រង់ព្រះអង្គជាដុំអ្នកតាទេ គឺនៅតែក្តាប់អំណាចផ្សេងៗ មកទុកក្នុងព្រះហស្តព្រះអង្គ ពោលគឺទ្រង់ជាសមាជិកម្នាក់របស់សភាព្រស្ត ទ្រង់ជាអ្នកបញ្ជាការកងទ័ព ទ្រង់ជាអ្នកឧបត្ថម្ភសាសនា, នឹងទ្រង់ជានាយកនៃសភាសេណាត់ ទ្រង់សំដែងសុន្ទរកថាក្នុងទីប្រជុំសេណាត់ដូចជាសមាជិកសភា ទ្រង់បោះឆ្នោតក្នុងសភាព្រស្តដូចជាព្រស្តិដែរ ។ វិធីនេះជាវិធីឆ្លាតបំផុត ព្រោះទ្រង់រួបរួមក្រុងរោមទាំងមូលមកទុកក្នុងព្រះហស្តបាន ឥតនរណាដឹងខ្លួនថាទ្រង់ធ្វើដូច្នោះឡើយ ឯសភាទាំងពីរនឹងធ្វើការអ្វីឲ្យលើសពីព្រះបំណងរបស់ទ្រង់ទៅពុំបានឡើយ ហេតុនេះទើបគួរនឹងពោលថា ព្រះបាទអូគុស្តសេសារជាមហាក្សត្រ ១ អង្គ ដែលទ្រង់ធ្វើឲ្យប្រជាជនយល់ថាទ្រង់ជាក្សត្រឥតអំណាចរាជសក្តិអ្វីឡើយ តែការពិតទ្រង់ជាក្សត្រអាជ្ញាសិទ្ធិពេញ ។

## អំពីក្រុងរោមក្រោមអំណាចមហាក្សត្រអូគុស្ត

តាំងពីតាំងជារាជអាណាចក្រឡើង ក្រុងរោមក៏មានសេចក្តីចំរើនឡើងច្រើន ទាំងប្រាសាទរាជស្ថាន ទាំងអក្សរសាស្ត្រ ហើយបានកសាងជាវិវត្តសំខាន់ៗ ឡើងជាច្រើន មានពួកអ្នកប្រាជ្ញសំខាន់ៗ កើតឡើងដូចជាមេសែន (Mécéne) ជាអ្នកប្រាជ្ញអក្សរសាស្ត្រ ទីត-លីវ អ្នកប្រាជ្ញពង្សាវតារ (Tite-Live) និងអ្នកប្រាជ្ញខាងចិន្តកវី មានវ៉ឺស៊ីល, ហូរ៉ាស

(Vigile et Horace) ជាដើម ជាគ្រឿងប្រដាប់កិត្តិយសរបស់មហាក្សត្រ ។ ចំណែកខាងប្រជារាស្ត្រក៏ប្រកបដោយសេចក្តីសុខសប្បាយ ប្រហែលសម័យស៊ុលសេសារដែរ ។

ព្រះបាទអូគុស្តសេសារ មិនមានព្រះរាជឱរស ទើបទ្រង់តាំងកូនរបស់អាគ្រីប្ប៉ា ដែលជាសំឡាញ់រួមសុខរួមទុក្ខរបស់ទ្រង់ ក្នុងខណៈដែលច្បាំងនឹងអង់ត្វាន នោះឲ្យឡើងទៅជារជ្ជទាយាទ (សិទ្ធគ្រងរាជសម្បត្តិ) តែកូនរបស់អាគ្រីប្ប៉ាអនិច្ចកម្មទៅមុន ទើបទ្រង់ប្រគល់ដំណែងនេះដល់ទីបែរ ដែលជាកូនចិញ្ចឹមរបស់ព្រះអង្គ គឺជាកូនរបស់ព្រះជាយាដែលជាប់មកពីប្តីចាស់ ។ ព្រះបាទអូគុស្តសេសារមានព្រះជន្មាយុ ៧៦ វស្សា ទើបទ្រង់ទិវង្គតទៅ ក្នុងពុទ្ធសករាជ ៥៥៧ (ក្រោយ គ.ស. ១៤ ឆ្នាំ) ។ ក្រុងរ៉ូមរៀបពិធីសពរបស់ទ្រង់ មិនបានដុតបូជាដូចសម័យបុរាណទេ គឺគេយកទៅកប់ទុក ។

រាជបល្ល័ង្កក្រុងរ៉ូមបានមកដល់ទីបែរដោយរៀបរយ ទាំងប្រជាជនក៏ពេញចិត្តនឹងរបៀបត្រួតត្រាបែបនេះ ព្រោះតាំងពីចាប់ធ្វើការតាមរាជាធិបតេយ្យឡើងកាលណា ក្រុងរ៉ូមក៏ស្ងប់ស្ងាត់រៀបរយ ហើយប្រជាជនគ្រប់ជាន់ក៏ធូរស្រួលសប្បាយឡើងជាងកាលពីមុន ។ ឯព្រះបាទទីបែរក៏ទ្រង់បន្ថយអំណាចរបស់ទ្រង់ ឲ្យតូចជាងព្រះបាទអូគុស្តសេសារទៅទៀត

គឺគ្រាន់តែទទួលដំណែងជាអធិបតីនៃសភាសេណាត់ប៉ុណ្ណោះ ឯដំណែងដទៃៗទៀត ទ្រង់តាំងអ្នកដទៃទៀតជំនួសទាំងអស់ ។ ដ្បិតទីបេរនេះចូលមកទទួលរាជសម្បត្តិ ក្នុងវេលាទ្រង់មានព្រះជន្មដល់ ៥០ វស្សាហើយ ទើបទ្រង់មិនប្រាថ្នាបុណ្យអំណាចរាជសក្តិយ៉ាងធំទេ ទីបេរជាក្សត្រទ្រង់ប្រកបដោយយុត្តិធម៌ ១ តែតមកក្រោយមានព្រះសតិមិនប្រក្រតី ក្លាយទៅជាមនុស្សពោសោច្រើន បានសម្លាប់មនុស្សជាចំនួនច្រើនណាស់ ទីបេរទ្រង់ទិវង្គតទៅក្នុងពុទ្ធសករាជ ៥៨០ (គ.ស. ៣៧) ។

អ្នកដែលទទួលរាជសម្បត្តិជាបន្ទាប់មក ឈ្មោះកាលីគុឡា (Caligula) ។ ដំបូងជាក្សត្រទ្រទ្រង់យុត្តិធម៌ល្អ តែច្រើនមានអាពាធប្រចាំរាងកាយហើយក្លាយទៅជាឆ្កួត ចាយវាយប្រាក់កាសខ្ជះខ្ជាយ ដូចជាឲ្យយកគោមជាចំនួនច្រើនទៅអុជបំភ្លឺលេងលើខ្នងភ្នំ ធ្វើការងារដូចជាក្មេងមិនទាន់លែងដោះ ដូចជាតាំងឲ្យសេះរបស់ខ្លួនធ្វើជាកុងស៊ុលជាដើម ។ លុះតមកទើបពួកទាហានរួបរួមគ្នាតាំងមនុស្សម្នាក់ឡើង ឲ្យឡើងសោយរាជឈ្មោះក្លោត (Claude) គេទុកជាក្សត្រអគ្គដំបូងដែលពួកទាហានតាំងឡើង ក្សត្រថ្មីនេះមិនមានចំណេះចេះដឹងមាំមួនទេ បានរៀបមង្គលការនឹងស្ត្រីមេម៉ាយម្នាក់ឈ្មោះអាគ្រីព្ពីណា (Agrippina) មានកូនជាប់មកពីប្តីចាស់ម្នាក់ផង ។ តមកព្រះនាងអាគ្រីព្ពីណា លបដាក់ថ្នាំបំពុលសម្លាប់ព្រះរាជស្វាមី គឺព្រះបាទក្លោតបង់ទៅ ដើម្បីឲ្យកូនរបស់ព្រះនាងឡើង

សោយរាជ្យ ហើយខ្លួនព្រះនាងជាអ្នកសម្រេចរាជការផែនដី ។ ឱរសរបស់ព្រះនាងអាគ្រីពីណា នេះ ឈ្មោះនេរ៉ុង (Néron) ជាក្សត្រមានកេរ្តិ៍ឈ្មោះល្បីល្បាញបំផុតមួយរបស់ក្រុងរោម តែជាកេរ្តិ៍ឈ្មោះខាងអាក្រក់ ៗ

កាលព្រះបាទនេរ៉ុងឡើងសោយរាជ្យនោះ ទ្រង់មានព្រះជន្មត្រឹម ១៧ វស្សា ព្រះនាងអាគ្រីពីណា ជាអ្នកសម្រេចរាជការ មានអ្នកប្រាជ្ញម្នាក់ឈ្មោះសេណែក (Sénèque) ជាអ្នកជំនួយនិងប៊ុរ្រុស (Burrhus) ជាមេទ័ព ។ លុះនេរ៉ុងធំឡើង មិនព្រមឲ្យព្រះជននីជួយសម្រេចរាជការតទៅទៀត ថែមទាំងរកឧបាយសម្លាប់ម្តាយខ្លួនបង់ទៅផង គឺដំបូងឲ្យយកព្រះជននីទៅបោះចោលក្នុងសមុទ្រទៅ តែព្រះជននីមិនស្លាប់បានទាំហែលទឹករស់រួចជីវិតមកបាន ទើបនេរ៉ុងទ្រង់បង្គាប់ឲ្យមនុស្សទៅចាប់ចាក់សម្លាប់ទៅ ទុកជាបាបធំបំផុតដែលនេរ៉ុងបង្គាប់ឲ្យធ្វើនេះ នេរ៉ុងនៅតែប្រព្រឹត្តអាក្រក់សាហាវតទៅទៀត គឺឲ្យចាប់ព្រះអគ្គជាយារបស់ទ្រង់យកទៅសម្លាប់ ហើយប្រព្រឹត្តបទអាក្រក់ផ្សេងៗ ជាមនុស្សស្រវឹងខ្លួបដើរលេងល្ខោនផ្តេសផ្តាសក្នុងទីប្រជុំជន ដែលក្សត្រប្រកាន់ថាជាអំពើថោកទាបបំផុត ។ ក្នុងរជ្ជសម័យនៃក្សត្រនេះ កើតភ្លើងឆេះក្រុងរោម ១ គ្រាយ៉ាងធំ មានពាក្យចំណាលថា នេរ៉ុងជាអ្នកបង្គាប់ឲ្យដុត ដើម្បីបំផ្លាញពួកអ្នកកាន់សាសនាគ្រិស្ត ដែលទើបកើតឡើងនៅក្រុងរោម ។

នេរ៉ុងប្រព្រឹត្តអាក្រក់សាហាវបែបនេះជាវេលា ១៣ ឆ្នាំ នៅទីបំផុតពួកទាហានផ្សេងៗ ដែលនៅក្រៅក្រុងរោមនាំគ្នាបះបោរឡើង នេរ៉ុងរត់ចេញទៅនៅស្រុក១ ហើយធ្វើអត្តវិនិបាតកម្ម (សម្លាប់ខ្លួនឯង) ក្នុងពុទ្ធសករាជ ៦១១ (គ.ស. ៦៨) ។

កប់តាំងអំពីសម័យនេរ៉ុងតទៅទៀត ជាវេលា ១៤២ឆ្នាំមានក្សត្រគ្រងរាជ្យជាជំណាក់គ្នាជាច្រើនអង្គ ហើយក្រុងរោមសម័យនេះ ក៏ប្រែប្រួលផ្លាស់ប្តូរប្លែកជាងសម័យបុរាណជាច្រើន ពោលគឺជាស្រុកគិតតែខាងការសប្បាយរីករាយ ដើរលេងស៊ើបកំសាន្តទីងពាយរាយខ្ជះខ្ជាយក្នុងវេលា ១ ឆ្នាំ ក្រុងរោមមានថ្ងៃធ្វើបុណ្យដល់ទៅ ១៧៥ថ្ងៃ (ស្ទើរតែក្នុង ២ថ្ងៃមានថ្ងៃធ្វើបុណ្យ ១ថ្ងៃ សុទ្ធតែជាថ្ងៃដែលពួករោមាំងធ្វើបុណ្យសម្ពោធផ្សេងៗ) ក្រុងរោមមានមន្ទីរល្ខោន ១ ធំសំបើម ចុះមនុស្សអង្គុយមើលជាចំនួន ៣០០.០០០ នាក់ ល្បែងដែលគេនិយមណាស់ក្នុងគ្រានោះគឺការងូតទឹក សង់មានរូបគំនូរតមកដល់សព្វថ្ងៃនេះ បន្ទប់ងូតទឹកជាបន្ទប់ធំសំបើមអស្ចារ្យ មានភ្លើងបង្កាត់ទុកពីខាងក្រោមសម្រាប់កំដៅបន្ទប់និងទឹក មានកន្លែងខាំងទប់ទឹកសម្រាប់ឲ្យមនុស្សទាំងឡាយស្រាតចុះងូតជាមួយគ្នាមិនបាច់មានអៀនខ្មាសគ្នាទេ ពួករោមាំងគិតតែនាំគ្នាស្វែងរកសេចក្តីក្សេមក្សាន្តគ្រប់យ៉ាង ដើម្បីឲ្យមានសំរើបខាងកាមតណ្ហា

ការស្រេបស្រាលនេះហើយដែលធ្វើឲ្យជាតិរ៉ូមាំងធ្លាប់ជាមហាអំណាចមកនោះ ត្រូវតែសាបសូន្យថយខ្សោយអំណាចទៅវិញ ។

បើរាប់តាំងអំពីព្រះបាទអូគុស្តសេសារ កាលពីពុទ្ធសករាជ ៥១២ រហូតមកដល់ពុទ្ធសករាជ ៧៣៥ មានស្តេចល្អៗ ចំនួន ៥ អង្គ ដែលសមគួរពោលទុកនៅទីនេះ ២ អង្គគឺព្រះបាទត្រាស៊ង់ (Trajan) ដែលទ្រង់ធ្វើការផ្សេងៗ ដែលជាប្រយោជន៍ដល់សាធារណជន ដូចជាបាត់ការទំនុកបំរុងពាណិជ្ជកម្ម ក្សេត្រកម្ម, រចនាទីងអក្សរសាស្ត្រឲ្យចំរើនឡើង ហើយជាក្សត្រអង្គដំបូងដែលទ្រង់រៀបចំក្រសួងរាជការសម្រាប់ជួយទំនុកបំរុងក្មេងកំព្រានឹងទាល់ក្រ ក្សត្រអង្គនេះគេរាប់ថា ទ្រង់មានព្រះទ័យសប្បុរសល្អជាបំផុត ទាល់តែមានទំនៀមតមកក្រោយៗ កាលបើមានក្សត្រឡើងសោយរាជសម្បត្តិ សភាសេណាត់រៀបចំធ្វើពិធីថ្វាយព្រះពរជ័យនឹងថ្វាយឧវាទដល់ក្សត្រអង្គថ្មីថា "សូមឲ្យទ្រង់ប្រកបដោយសេចក្ដីសុខសម្រាន្ត ក្រៃលែងជាងព្រះបាទអូគុស្តសេសារ នឹងសូមឲ្យទ្រង់ប្រកបដោយកុសលវត្តយ៉ាងប្រសើរក្រៃលែងជាងព្រះបាទត្រាស៊ង់" ។ ព្រះបាទត្រាស៊ង់ទិវង្គតក្នុងពុទ្ធសករាជ ៦៦០ (គ.ស. ១១៧) ។

ឯក្សត្រ ១ អង្គទៀត គឺព្រះបាទម៉ារ-អូរ៉ែល (Mare-Aurèle) ជាអ្នកប្រាជ្ញ នឹងទ្រង់ឧបត្ថម្ភពួកខ្ញុំ (ទាសា - ទាសី) នឹងទ្រង់តាំងស្ថានកុសលឡើងជាចំនួនច្រើន ពួកគ្រិស្តាំងមានសេចក្ដីសរសើរក្សត្រអង្គ

នេះច្រើន ដ្បិតទ្រង់ជាក្សត្រដំបូង ដែលទ្រង់ទំនុកបំរុងនឹងជួយផ្សាយលទ្ធិសាសនានេះ ។

ក្រៅពីក្សត្រពីរអង្គនេះ ក៏មានក្សត្រអង្គខ្លះ ដែលទ្រង់ធ្វើសេចក្តីល្អជាដំណាតមកក៏មាន ក្សត្រអង្គខ្លះធ្វើដេសដាសឆ្កួតវង្វេងដូចយ៉ាងនេរ៉ុងក៏មាន ។ តាំងអំពីព្រះបាទម៉ារ-អូរ៉ែលទិវង្គតទៅ គ.ស. ១៧៨ ក្រុងរោមចាប់ផ្តើមទ្រុឌទ្រោមអាប់ឱន មានព្រះរាជឱរសទទួលរាជសម្បត្តិជាដំណាតមក ទ្រង់ព្រះនាម កុមមោត (Commode) តែត្រូវគេធ្វើគុត ក្នុងពុទ្ធ-សករាជ ៧៣៥ (គ.ស. ១៩២ ។

---

# ភូមិសាស្ត្រនានាប្រទេស

## ប្រទេសអាមេរិកខាងត្បូង

ខ្នាតប្រទេស – បណ្តោយវែងបំផុត ៧,៣៤៣ គីឡូម៉ែត្រ ទទឹងធំបំផុត ៤,៨៦១ គីឡូម៉ែត្រ ។ ទំហំដីទាំងមូលប្រមាណ ១៧,៧៤៨,៣៦០ គីឡូម៉ែត្រក្រឡា ។

ផ្ទៃផែនដី – ប្រហែលប្រទេសអាមេរិកខាងជើង មានជួរភ្នំធំមហិមាដែលជាភ្នំមានខ្នាតវែងបំផុតក្នុងលោក ហៅថាករឌីយែរដេសអង់ដ៍ (វែងជាង៦,៤០០ គីឡូម៉ែត្រ) តាំងនៅលើដីរាបខ្ពស់ទិសខាងលិច ហើយខាងកើតមានដីរាបល្វឹងយ៉ាងធំទូលាយនៅកណ្តាលប្រទេស ។ ខាងមាត់ច្រាំងសមុទ្រត្រើយខាងកើត មានជួរភ្នំតូចៗ ជាច្រើនតាំងនៅលើដីរាបខ្ពស់ បន្ទាប់ពីភ្នំអស់នោះទៅជាទីទំនាបទល់នឹងមហាសមុទ្រអត្លង់ទិក ។

ភ្នំ – កំពូលភ្នំដែលខ្ពស់បំផុតក្នុងទ្វីបនេះ មាននៅក្នុងប្រទេសស៊ីលី មានកំពស់ ៦,៨៦០ ម៉ែត្រ ក្នុងប្រទេសប្រេស៊ីល មានភ្នំជាច្រើនត្រង់ភាគកណ្តាល និងភាគខាងកើត ។

ទីដីរាប – មានច្រើនអន្លើហៅឈ្មោះប្លែកៗគ្នាគឺ:

១ – ឡាណូស ជាទីរាបនៅដងទន្លេអូរេណូក៍

២ – ស័ល្វាស – ជាទីដីរាបនៅដងទន្លេ អាម៉ាសូន ទីរាបនេះមានព្រៃព្រឹក្សាជាច្រើន ។

៣- ក្រង់សាគូ ជាទីដីរបាយខ្សាច់ នៅចន្លោះបោលីវីប៉ារ៉ាក្វៃ និងអាសង់ទីន មិនសូវមានរុក្ខជាតិដុះលូតលាស់ល្អទេ ។

៤- ប៉ម្ប៉ា ជាវាលស្មៅយ៉ាងធំ ជាទីចិញ្ចឹមសត្វធ្វើស្រែនៅចន្លោះភ្នំធំនិងទន្លេប៉ារ៉ាណា ។

៥- សមុទ្រក្រួស នៅក្នុងដែនប៉ាតាកូនី ភាគខាងត្បូងស្រុកអា-សង់ទីនមិនសូវមានមនុស្សនៅ មិនសូវមានភ្លៀងធ្លាក់ផង ។

៦- សមុទ្រខ្សាច់ នៅក្នុងប្រទេសស៊ីលី តំបន់នេះស្ទើរតែមិនមានភ្លៀងធ្លាក់សោះឡើយ មិនមានរុក្ខជាតិដុះទេ ។

ទន្លេ — ទន្លេវែងៗ ក្នុងអាមេរិកខាងក្រោមនោះ សុទ្ធតែហូរធ្លាក់ទៅក្នុងសមុទ្រទិសខាងកើតទាំងអស់ ឯទន្លេសំខាន់ៗនេះមាន ៤ អន្លើ គឺ:

១ អាម៉ាសូន ដើមទឹកកើតពីភ្នំ ហូរធ្លាក់ទៅក្នុងមហាសមុទ្រអត្លង់ទិកក្នុងប្រទេសប្រេស៊ីល ទន្លេនេះបណ្ដោយវែងណាស់ ប្រមាណ ៦,១៦៦ គីឡូម៉ែត្រ មានដៃទន្លេជាង ២០០ អន្លើ ហូរធ្លាក់ចុះទៅក្នុងទន្លេៗនេះជាទន្លេធំបំផុតក្នុងលោក មានខ្នាតវែងជាទី ២ ក្នុងលោក មានកប៉ាល់តូច-ធំចេញចូលបានរហូត តាំងពីមាត់ទន្លេរហូតដល់ប្រទេសប៉េរូ ។

២- ប៉ារ៉ាណា ជាទន្លេមានខ្នាតវែងទី ២ ក្នុងអាមេរិកខាងត្បូងខាងក្រោមប្រមាណ ២,៦៨០ គីឡូម៉ែត្រ ។

៣ អូរេនោក ខាតវែង ២,២៤០ គីឡូម៉ែត្រ ហូរកាត់ប្រទេសវេនេស៊ុអេឡា ។

៤ សង់ហ្វ្រង់ស៊ិស្កូ ខាតវែង ១,៦០០ គីឡូម៉ែត្រ នៅក្នុងប្រទេសប្រេស៊ីល ។

អាកាស — ទ្វីបអាមេរិកខាងត្បូងមានផែនដីជាប់នឹងតំបន់មានអាកាសក្តៅដល់ទៅ ២ ភាគក្នុង ៣ ភាគ ទើបមានអាកាសក្តៅច្រើន វៀរលែងតែទីកបខ្ពស់ទិសខាងលិចក្នុងប្រទេសស៊ីលី នឹងអាសង់ទីន ទើបមានអាកាសអ៊ុនល្អ ។

ភ្លៀង — ខ្យល់ដែលនៅទិសខាងកើតទៀងខាងត្បូងជាខ្យល់បក់យកទឹកភ្លៀងអំពីសមុទ្រអត្លង់ទិក ឲ្យមកធ្លាក់នៅក្នុងទ្វីបអាមេរិកខាងត្បូង ។ ភ្លៀងនេះច្រើនធ្លាក់នៅតាមភ្នំ នឹងទីកបខ្ពស់ ក្នុងប្រទេសប្រេស៊ីល នឹងក្នុងប្រទេសគុយយ៉ាន នឹងក្នុងវេនេស៊ុអេឡា ។ មិនសូវមានភ្លៀងធ្លាក់នៅកណ្តាលទ្វីបទេ នៅចំណែកខាងមហាសមុទ្រប៉ាស៊ីហ្វិក ភ្លៀងក៏ជាប់នៅត្រឹមជួរភ្នំកម្ពស់ខ្ពស់ណាស់ ធ្វើឲ្យផែនដីកណ្តាលមិនសូវមានភ្លៀងសោះឡើយ ។

ដំណាំ — ដំណាំសំខាន់ដែលដាំច្រើន គឺកៅស៊ូ, កាហ្វេ, អំពៅ, ថ្នាំជក់, កាកាវ, គ្រឿងទេស, កប្បាស, ត្រី, ស្រូវផ្សេងៗ ។

សត្វ — សត្វព្រៃ មានស្វា, ប្រមា, ខ្លាឃ្មុំ, ខ្លាឃ្មុំ, ពស់ផ្សេងៗ សេក, សារិកា, ក្ងោក, ។ល។ សត្វស្រុក មានសេះ ពែះ គោ, និងឡាម៉ា

លោហធាតុ — មានបរិបូណ៌ទៅ តែមិនសូវមានអ្នកជីកយកមកប្រើការទេ លោហធាតុដែលគេបានច្រើន គឺ ពេជ្រ, ទង់ដែង ។

ប្រជាជន — ប្រមាណ ៨៣,៤៣១,៥០០នាក់ ច្រើនតែជាពួកឥណ្ឌៀននិងពួកមិទីហ្ស (ពួកកូនកាត់អាពុកជាជាតិខុរុបម្ដាយជាអ្នកស្រុក) ក្រៅពីនេះជាពួកអេស្ប៉ាញ៉ុល, ព័រទុគេស, នៃក្រ ។

ឯជាតិដែលមកពីប្រទេសដទៃមកនៅគេស៊ី មានជាតិអាល្លឺម៉ង់, ជប៉ុន, អ៊ីតាលី, និងអង់គ្លេសជាច្រើន ។ ជនអស់នោះច្រើនតែកាន់លទ្ធិសាសនាកាតូលិក ។ ភាសាអេស្ប៉ាញ៉ុលជាភាសាកណ្ដាលរបស់ពួកទ្វីបអាមេរិកខាងក្រោម តែពួកប្រេស៊ីលប្រើភាសាព័រទុគេស ។

ឯប្រទេសផ្សេងៗ នៅកន្ទ្វីបអាមេរិក ខាងក្រោមនេះ មានប្រទេសរេពុយព្លិក ១០ ប្រទេសនិងដែន ៣ ដែន ដែលជាចំណុះប្រទេសឯទៀតៗ ដូចមានកាយឈ្មោះខាងក្រោមនេះ គឺ:

| ប្រទេស | ទំហំដី | ចំនួនមនុស្ស | ទីក្រុង |
|---|---|---|---|
| ប្រេស៊ីល | ៨.៥៥០.០០០ក.ម. | ៤៦.០១០.០០០ | រីអូដឺស័នេរ៉ូ |
| អាសង់ទីន | ៣.០០០.០០០ " | ១២.៨០០.០០០ | ប៊ុយណុសអៃរ៉ុស |

| ប្រទេស | ទំហំដី | ចំនួនមនុស្ស | ទីក្រុង |
|---|---|---|---|
| ស៊ុលី | ៧៥១.៦៥០ ក.ម. | ៤.៣០០.០០០ | សន្ទីអាកូ |
| ប៉េរូ | ១.២៤៩.០០០ " | ៦.២០០.០០០ | លីម៉ា |
| បូលីវី | ១.៥៦៨.១០០ " | ៣.០៦៦.៩០០ | ស៊ុក្រែ |
| កូឡុម្ប៊ី | ១.៤៦១.៧៩០ " | ៩.០០០.០០០ | ប៉ោគូតា |
| វេនេស៊ុអេឡា | ៩៤២.០០០ " | ៣.២៦២.០១. | កាក៉ាស |
| អេក្វាទ័រ | ៤៤៣.៧៩០ " | ២.៦០០.០០០ | គីតូ |
| ប៉ារ៉ាគ័យ | ១៥៩.៨៣០ " | ៨៧០.២០០ | អាស៊ុងស្យុង |
| ឩរុក័យ | ១៨៧.០០០ " | ២.០២ .៩៤០ | ម៉ុងតេវីដេអូ |
| គុយយ៉ាន (អង់គ្លេស) | ២៣១.៧៥០ " | ៣៩២.៥១. | ស៊ិកតូហ៊ូ |
| គុយយ៉ាន (ហុល្លង់) | ១៤០.៦១១ " | ១៧០.០០០ | ប៉ារ៉ាម៉ារិបូ |
| គុយយ៉ាន (បារាំងសែស) | ៨៨.៩៧១ " | ៤៧.៥០០ | កាយែន |

## ភូមិសាស្ត្រសង្ខេប

## ប្រទេសប្រេស៊ីល

ខ្នាត — ប្រេស៊ីលជាប្រទេសដែលមានខ្នាតធំ ជាងប្រទេសដទៃៗ ទាំងអស់ ក្នុងទ្វីបអាមេរិកខាងក្រោម មានទំហំដីធំជាងសហរដ្ឋអាមេរិក ដល់ ៨ សែនគីឡូម៉ែត្រក្រឡា ។

អាកាស — ធាតុអាកាសមធ្យមនៅក្នុងចន្លោះ ៦៣° ដល់ ៧៩° ។ មានភ្លៀងធ្លាក់ច្រើន (ពី ១២៧០-២៥៤០ មិល្លីម៉ែត្រ ។

ដំណាំ — កាហ្វេ (ច្រើនបំផុតក្នុងលោក) កាកាវ (ជាទី២ក្នុងលោក), កៅស៊ូ, អំពៅ, ពោត, ស្រូវ, ថ្នាំជក់, កប្បាស, ដំឡូង, ទំពាំងបាយជូរ, និងឈើផ្សេងៗ ។

សត្វ — ចំនួនសត្វក្នុង ព.ស. ២៤៧៥ មានដូចេះ: គោ ៤២ លាន ជ្រូកប្រមាណ ២១ លាន, ពពែ ១០ លាន សេះ ៦ លាន ពពែ ៥ លាន លានិងលាផាង ២ លាន ។

រ៉ែ — មាននៅក្នុងប្រទេសប្រេស៊ីល មានច្រើនជាងប្រទេសឯទៀតៗ ទាំងអស់ ក្នុងទ្វីបអាមេរិកក្រោម ។

លោហធាតុ — ប្រេស៊ីលមានពេជ្រត្បូង, មាសនិងដែកយ៉ាងបរិបូណ៌ ម៉ង់កាណែសជាលោហធាតុសំខាន់បំផុត ។

ជំនួញលក់ចេញ — កៅស៊ូជាជំនួញដែលលក់ចេញមានដំឡៃច្រើនបំផុត ជំនួញសំខាន់មួយទៀត គឺកាហ្វេ មានចំនួនដល់៦៥% នៃជំនួញកាហ្វេ ក្នុងលោក ។ ជំនួញបន្ទាប់មក គឺ កាកាវ, សាច់សត្វ, តែ, ស្ករ, ថ្នាំជក់, កប្បាស, ស្បែកសត្វ, ឈើ, ពេជ្រ, មាស, និងខ្លាញ់គោ ។

ប្រទេសប្រេស៊ីល — ធ្វើជំនួញនឹងសហរដ្ឋអាមេរិក, អង់គ្លេស, អាល្លឺម៉ង់, បារាំងសែស ។

ជំនួញលក់ចូល – សំពត់អម្បោះ, គ្រឿងដែក, គ្រឿងម៉ាស៊ីន, សំពត់រោមសត្វ, ធ្យូងថ្ម, គ្រឿងធ្វើពីស្បែក ។

ផ្លូវគមនាគម – មានផ្លូវរថភ្លើង ៣៥, ៦៤៦ គីឡូម៉ែត្រ (ព.ស. ២៤៧៦) ថ្នល់វែង ២១,៣២៨ គីឡូម៉ែត្រ ។

របៀបត្រួតត្រាស្រុក – មានប្រធានាធិបតីជាអ្នកប្រើអំណាចត្រួតត្រារួមជាមួយនឹងគណៈរដ្ឋមន្ត្រី ។ រដ្ឋសភាដែលប្រកបដោយសភាជាន់ខ្ពស់ និងសភាដំណាងរាស្ត្រ ជាអ្នកបញ្ញត្តិច្បាប់ ឯសមាជិកនៃសភាទាំងពីរនោះនៅក្នុងដំណែងម្នាក់ ៤ ឆ្នាំ ប្រហែលនឹងប្រធានាធិបតី ។ រេពុយព្លិកប្រេស៊ីលនេះធ្វើតាមរបៀប សហរដ្ឋអាមេរិក ប្រទេសនេះប្រកបដោយរដ្ឋផ្សេងៗ រួម ២០ រដ្ឋ រដ្ឋអស់នេះមានរដ្ឋសភានិងរដ្ឋបាលរបស់ខ្លួនឯង ដោយបណ្ដារាស្ត្ររើសតាំងឡើង បណ្ដារាស្ត្រទាំងប្រុសទាំងស្រីដែលមានអាយុតាំងពី ១៨ ឆ្នាំឡើងទៅមានអំណាចបោះឆ្នោតរើសតាំងដំណាងរាស្ត្រនិងប្រធានាធិបតី ។

ទីក្រុងសំខាន់ៗ – រីយ៉ូដឺសានេរ៉ូ ជាទីក្រុងនិងជាស្រុកសំខាន់បំផុត ហើយជាស្រុកល្អបំផុតនៅទ្វីបអាមេរិកខាងត្បូង មានចំនួនមនុស្ស ១.៤៦៨.៧០០ នាក់ ។ កាហ្វេលក់ចេញអំពីស្រុកនេះច្រើន ។ សង់-តូស ជាស្រុកកំពង់និងជាស្រុកធំទីពីរ មានកាហ្វេលក់ចេញច្រើនជាង

ស្រុកឯទៀតៗ ប៉ែណាំប៊ុគនិងបាហៀ ជាកំពង់លក់កប្បាស, ក្រាវប៉ាក់និងម៉ាក់នញ៉ោវ ជាកំពង់លក់កៅស៊ូនិងរបស់ព្រៃផ្សេងៗ សាវប៉ូលោ ជាស្រុកធំមានការលក់ផូវច្រើន, ម៉ាណាអូស ជាស្រុកសំខាន់ក្នុងដងទន្លេអាម៉ាសូន, ឪយ៉ោម៉ង់ទីណា ជាទីប្រជុំលក់ពេជ្រនិងថ្មពេជ្រ នៅក្នុងចន្លោះភ្នំប្រ៊ាំងកានិងភ្នំអេសពីញ៉ាសូ ។

## ភូមិសាស្ត្រសង្ខេប

## ប្រទេសអាសង់ទីន

ផ្ទៃដែនដី – ជាទីដីរាបដ៏ធំទូលាយ មិនសូវមានភ្នំទេ ក្រៅពីមហាភ្នំករឌីយេរដេសង់ដ៏ដែលនៅព្រំប្រទល់ដែនទិសខាងលិច ទីដីរាបក្រង់សាកូនៅទិសខាងជើង វាលស្មៅប៉ម្ប៉ានៅភាគកណ្ដាល សមុទ្រក្រួសនៅខាងក្រោម ទន្លេធំៗ គឺទន្លេប៉ារ៉ាណានិងអុរុក្វៃ (១៦០០កិឡូម៉ែត្រ) ដែលហូរមករួមគ្នាត្រង់ជិតដល់មាត់សមុទ្រ ត្រង់ដែលរួមគ្នានេះជាទន្លេយ៉ាងធំទូលាយហៅថា ឡាប្លាត ។

ខ្យល់អាកាស– នៅតំបន់ទៅក្រោមៗទៅ មានអាកាសត្រជាក់ ពពកចុះច្រើនហើយភ្លៀងក៏ធ្លាក់ច្រើន នៅតំបន់ខាងលើមានអាកាសអ៊ុនល្អ មានភ្លៀងធ្លាក់ច្រើន នៅតំបន់ទិសខាងកើត ទន្លេប៉ារ៉ាណា ។

ដំណាំ — ពោតជាដំណាំដែលដាំច្រើនបំផុត ស្រូវប៊្លេជាទីពីរ និង ដំណាំយ៉ាងដទៃទៀត មានស្មៅ, ទំពាំងបាយជូរ, ដំឡូងបារាំង, ថ្នាំជក់, អំពៅ, កប្បាស, តែ ។

សត្វ — ក្នុង ព.ស. ២៤៧៣ មានចំនួនសត្វដូច្នេះ គឺកែះ ៤៤.៤១៣.២២១ គោ ៣២.២១១.៨៥៥ សេះ ៩.៨៥៨.១១១ ពពែ ៥.៦៤៧.៣៩៦ ជ្រូក ៣.៧៦៨.៧៣៨ ។

ប្រទេសនេះចិញ្ចឹមកែះ, ពពែ, លា, និងសេះច្រើនជាងប្រទេសដទៃ ៗ នៅទ្វីបអាមេរិកខាងក្រោម ចំពោះកែះមានចំនួនច្រើន ជាងប្រទេសនានាទាំងអស់ក្រៅពីអូស្ត្រាលី ។

លោហជាតុ — មានតែត្បូងថ្ម ១ មុខ ដែលជីកចេញបានក្រែល គ្រាន់បើ លោហជាតុដទៃទៀតមិនសូវមាន ។

ជំនួញដែលលក់ចេញ — ស្រូវប៊្លេ, ពោត, សាច់គោ, សាច់កែះ សត្វគោ, សត្វកែះ, រោមកែះ, បឿរ, ស្បែកសត្វ, ខ្លាញ់គោ ។ ជំនួញអស់នេះបញ្ជូនទៅលក់ប្រទេសអង់គ្លេស, បារាំងសែស, អាល្លឺម៉ាញ, បេល្ស៊ិក, និងសហរដ្ឋអាមេរិក ។

ជំនួញលក់ចូល — គ្រឿងសំលៀកបំពាក់, គ្រឿងដែក, គ្រឿងម៉ាស៊ីន, គ្រឿងកែវ, គ្រឿងចាន, ធ្យូងថ្ម, ក្រដាស, គ្រឿងប្រដាប់សម្រាប់ប្រើក្នុងក្សេត្រកម្ម, ឡាប៉ៃរ, សូត្រ, រថយន្ត ។

ផ្លូវគមនាគមន៍ — មានផ្លូវរទេះភ្លើងវែង ៤១,៤៥៨ គីឡូម៉ែត្រ ។ ផ្លូវវែង ២០៥,៩២០ គីឡូម៉ែត្រ រថយន្ត ១៦០,០១០ ។

របៀបគ្រប់គ្រងស្រុក — ជារបៀបរេពុយព្លីក ប្រហែលប្រទេសកាណាដា តែច្បាប់ព្រះគ្រឹមធម្មនុញ្ញរបស់អាស្ទ័ន ធ្វើតាមបែបសហរដ្ឋអាមេរិក ។ ប្រធានាធិបតីនៅក្នុងដំណែងកំណត់ ៦ ឆ្នាំ រដ្ឋសភាប្រកបដោយសភាជាន់ខ្ពស់និងសភាជំណាងរាស្ត្រ បណ្ដារាស្ត្របោះឆ្នោតរើសតាំងដូចសហរដ្ឋអាមេរិកដែរ ។

ស្រុកសំខាន់ — ប៊ុយណូសអៃរ៉េស ជាទីក្រុង មានមនុស្ស ១៨០០,០០០នាក់ ហើយជាស្រុកកំពង់ផែសំខាន់ផង ជាស្រុកធំបំផុតក្នុងទ្វីបអាមេរិកខាងក្រោម ។ ស្រុកឡាប្លាតា, រ៉ូសារីអូ, ជាស្រុកកំពង់ ។ កដូបា, ម៉ង់ដូសា ជាទីជំនុំលក់ដូរខាងជើងគោក ។

## ប្រទេសស៊ីលី

ខ្នាត — បណ្ដោយវែងបំផុត ៤.២៥៨ គីឡូម៉ែត្រ ទទឹងនៅក្នុងរវាង ៩៦ ដល់ ៤៣៧ គីឡូម៉ែត្រ ។

ផ្ទៃផែនដី — មានភាគផែនដីជម្រាលពីទិសខាងកើតទៅខាងលិច ហើយពីទិសខាងជើងទៅខាងត្បូង ។ ភាគខាងជើងជាទីស្ងួតក្រៀម

ព្រោះដាំដំណាំមិនកើត ភាគកណ្ដាលដាំដំណាំល្អ ហើយភាគខាងត្បូងស្ដុកទៅដោយព្រៃព្រឹក្សា ។

ទន្លេ – ម៉ៃប៉ូ, ប៊ីអូប៊ីអូ នឹងវ៉ាលឌីវីយ៉ា ជាទន្លេសំខាន់ ។

ដំណាំ – ដែលដាំជាច្រើន គឺស្រូវប៊្លេ នឹងស្រូវឯទៀតៗ, ទំពាំងបាយជូរ, ក្រូច, អូលីវ, បេតេរ៉ាវ កាហ្វេនឹងកប្បាស ។

លោហធាតុ – មានធាតុនីត្រាតសល់ផែត (ធាតុម្សៅ) ច្រើនបំផុតក្នុងលោក ជាលោហធាតុបញ្ជូនទៅលក់ទ្វីបឥរុប លោហធាតុយ៉ាងដទៃទៀត មានទង់ដែង, អ៊ីអូត, អម្បិល, បូរ៉ាក្ស, ប្រាក់, សំណប៉ាហាំង, ម៉ង់ហ្គាណែស, មាស, ស្ពាន់ធ័រ, អាចម៍សត្វ, ដែក, នឹងធ្យូងថ្ម ។ លោហធាតុផ្សេងៗ មានច្រើនក្នុងភាគខាងជើងនៃប្រទេស នីត្រាត មានច្រើនក្នុងសមុទ្រខ្សាច់ ។

សត្វ – មានកែះនឹងគោជាសំខាន់ក្នុង ព.ស. ២៤៧៣ មានកែះ ៦.២៦៣.៤៨២ គោ ២.៣៨៧.៩៤០ ពពែ ៧៨៨.៨៣១ សេះ ៤៤១.០២៧, ជ្រូក ៣៣១.១៥៦ ។

ជំនួញលក់ចេញ – ជំនួញលក់ចេញដែលសំខាន់បំផុតរបស់ស៊ី-លីមាន ២ យ៉ាងគឺ នីត្រាតនឹងទង់ដែង ជំនួញសំខាន់បន្ទាប់ចុះទៅ គឺ: រោមកែះ, ធាតុដែក, សាច់សត្វ, អ៊ីអូត, កាហ្វេ, កប្បាស, ធាតុ-ម៉ង់ហ្គាណែស, ស្ករ, កៅស៊ូ ។

ផ្ទៃក្រឡា - មានផ្ទៃក្រឡា ៣៩.០៦២ គីឡូម៉ែត្រ រឺ ប្រវែង ៨.៨៦៤ គីឡូម៉ែត្រ ។

របៀបគ្រប់គ្រងស្រុក - ធ្វើតាមរបៀបសហរដ្ឋអាមេរិក ប្រធានាធិបតី ត្រូវរាស្ត្របោះឆ្នោតរើសតាំងឡើងនៅក្នុងដំណែង ៦ ឆ្នាំ សមាជិកសភាជាន់ខ្ពស់ និងសមាជិកសភាជំណាងរាស្ត្រនៅក្នុងដំណែង ៤ ឆ្នាំ រដ្ឋមន្ត្រីមានចំនួន ៩ នាក់គោរពទទួលខុសត្រូវចំពោះប្រធានាធិបតីតែមួយ ។

ស្រុកសំខាន់ៗ - សង់ទីអាកូជាទីក្រុង វ៉ាល់ប៉ារ៉ៃសូជាស្រុកកំពង់សំខាន់បំផុត កូពីអាប៉ូ ជាទីប្រជុំជំរកលោហធាតុ ក្នុងសិបស្បែងទិនអ៊ែលឌីរ៉ែ ជាកំពង់កប៉ាល់ ។

## ប្រទេសឯទៀតៗ

បូលីវី - នៅទិសខាងលិចជាជួរភ្នំខ្ពស់ ជម្រាលទៅទិសខាងកើត មានទន្លេសំខាន់ឈ្មោះម៉ាដេរ៉ា ទីជម្រាលទិសខាងកើតជាទីវាលទំនាប, កាកាវ, កាហ្វេ, ស្រូវប៊ើ, ពោត, លើទីភ្នំខ្ពស់ ដាំដំឡូងបារាំង, ស្រូវបើ, ប្រទេសនេះមានសំណប៉ាហាំង, សំណ, ប្រាក់និងមាសបរិបូណ៌ច្រើន ។ សំណប៉ាហាំងជាផលនាំចេញសំខាន់បំផុត (៦៣%) ។ ទីក្រុងរបស់បូលីវី ហៅថា ស៊ូគ្រ៍ឡាប៉ាស់ជាស្រុកតាំងរដ្ឋសភា មានប្រជាជនទីង

ដំនួញច្រើនជាងប្រទេសឯទៀត ។ អ៊ូរុយរ៉ូជាកន្លែងជីកលោហធាតុ ។ ប្រធានាធិបតីនិងសមាជិកសភាដំណាងរាស្ត្រនៅក្នុងដំណែងបានត្រឹម ៤ ឆ្នាំ ឯសមាជិកសភាជាន់ខ្ពស់នៅក្នុងដំណែង ៦ ឆ្នាំ ។

ប៉េរូ - មានកប្បាស, កាហ្វេ, អំពៅ, កាកាវ, ស្រូវបើ, ស្រូវខ្សាយ, ពោត, ថ្នាំជក់, ទំពាំងបាយជូរ, កៅស៊ូ, ជាដំណាំសំខាន់ ។

លោហធាតុសំខាន់ - មានវុលហ្វ្រែម, ប៉េត្រូល ទង់ដែង, ប្រាក់, និងមានធ្យូងថ្មយ៉ាងស្តុកស្តម្ភ, ស្រុកលីម៉ាជាទីក្រុង ។ កាលគ្រាពីសារ៉ូមទីពអេស្ប៉ាញ៉ូលមកកាន់ប្រទេសនេះ ពោលថាពួកប្រទេសប៉េរូ ជាជាតិចំរើនរុងរឿង ជាងបណ្ដាជាតិទាំងអស់ដែលនៅអាមេរិកក្រោម ។ ដំនួញលក់ចេញដែលសំខាន់មានប្រេងប៉េត្រូល (ក្នុង ១ ឆ្នាំៗ លក់ចេញ ១.៥០០.០០០ តោន) ធ្យូងថ្ម ១៥០.០០០ តោន កប្បាស, ទង់ដែង, ស្ករ, ប្រាក់, ថ្នាំជក់, ស្បែកសត្វ ។

មានជ្ឈិវរបិភ្លើង - ៤,៤៩៦ គីឡូម៉ែត្រ របៀបត្រួតត្រាស្រុកប្រហែលសហរដ្ឋអាមេរិក ប្រធានាធិបតីសមាជិកសភាដំណាងរាស្ត្រនៅក្នុងដំណែងត្រឹម ៥ ឆ្នាំ ឯសមាជិកសភាជាន់ខ្ពស់នៅក្នុងដំណែង ៦ ឆ្នាំ ។

ប៉ារ៉ាក្វ័យ - មានតែ, ថ្នាំជក់, ស្រូវបើ, អំពៅ, ជាដំណាំដែលគេដាំខ្លះទៅ ។ ដំនួញលក់ចេញមានតែ, ស្បែកសត្វ, សាច់សត្វជាសំខាន់ ។

ស្រុកអាស៊ីនស្យ៊ែនជាទីក្រុង ។ ប្រធានាធិបតី, សភាជាន់ខ្ពស់ និងសមាជិកសភាដំណាងរាស្ត្រនៅក្នុងដំណែង ៤ ឆ្នាំ ។

អ៊ុរូហ្គ័យ- ក្សេត្រកម្មជារបស់សំខាន់របស់ប្រជាជន ស្រូវប៊ី, និងពោតគេដាំជាចំនួនច្រើន ។ សត្វមានគោនិងកែះ ទីក្រុងហៅថា ម៉ុងតេ-វីដេអូ, ស្រុកប៉ាយស័នឌុ, និងហ្វ្រៃបេនតុសមានរោងម៉ាស៊ីនធ្វើសាច់ដាក់កំប៉ុងជាច្រើន ។ ប្រធានាធិបតីនៅក្នុងដំណែង ៤ ឆ្នាំ សមាជិកសភាជាន់ខ្ពស់ នៅក្នុងដំណែង ៦ ឆ្នាំ សមាជិកសភាដំណាងរាស្ត្រនៅក្នុងដំណែង ៣ ឆ្នាំ ។

អេក្វាទ័រ – ជំនួញសំខាន់របស់ប្រទេសនេះមានកាកាវ, (ច្រើនបំផុត) កាហ្វេ, មាស, ប្រាក់ ។ ស្រុកក្វៃអាគីលជាស្រុកកំពង់ធំបំផុត គីតូជាស្រុកក្រុង ។ ប្រធានាធិបតីនិងសមាជិកសភាជាន់ខ្ពស់នៅក្នុងដំណែង ៤ ឆ្នាំ ឯសមាជិកសភាដំណាងរាស្ត្រនៅក្នុងដំណែង ២ ឆ្នាំ ។

កូឡុំប៊ី— ជំនួញលក់ចេញរបស់ប្រទេសនេះ គឺកាហ្វេ, (ច្រើនបំផុត) ស្បែកសត្វ, ថ្នាំជក់, កាកាវ, កៅស៊ូ, កប្បាស, ប្រាក់និងមាស ។ ទីក្រុងឈ្មោះបូកូតា មេដឹលជាស្រុកដែលមានការ ជីកធាតុប្រាក់និងធាតុមាសជាច្រើន ។ របៀបត្រួតត្រាស្រុកដូចប្រទេសអេក្វាទ័រ ។

វេណេស៊ុយអេឡា — ជាប្រទេសមានលោហធាតុជាសម្បត្តិយ៉ាងសំខាន់ (មានធាតុប្រេងច្រើនបំផុតក្នុងអាមេរិកក្រោម) មាស, ទង់ដែង,

ប្រាក់, ដែកនឹងអំបិលជាជំនួញលក់ចេញយ៉ាងសំខាន់ ៗ ជំនួញលក់ចេញយ៉ាងដទៃទៀត មានកាហ្វេ, កាកៅ, ស្ករ, ស្បែកសត្វ, គោ, ឈើជ្រលក់សំពត់ ៗ

ការ៉ាកាស - ជាស្រុកក្រង ស្រុកកំពង់មានដល់ទៅ ៣២ស្រុក ៗ ប្រធានាធិបតី នៅក្នុងដំណែង ៧ ឆ្នាំ ឯសមាជិកសភាជាន់ខ្ពស់ នឹងសភាដំណាងរាស្ត្រនៅក្នុងដំណែង ៣ ឆ្នាំ ៗ

គុយយ៉ាន - បែកចេញជា ៣ ផែន ជាចំណុះអង់គ្លេស, បារាំងសែស, នឹងហុល្ល័ង ទ្រព្យសម្បត្តិផែនដីដែលសំខាន់ មានកាហ្វេ, អំពៅ ថ្នាំជក់, ចេក, ស្រូវឡាយ, កប្បាស, ឈើ, មាស' ពេជ្រ, គ្រឿងទេស ៗ